# ឧប្បាតសន្តិ

## រចនាដោយព្រះសីលវំសមហាថេរ

**បរិវត្តដោយ ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន**

*ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*ព.ស.២៥៥៦*

| | |
|---|---|
| ឈ្មោះសៀវភៅ | ឧប្បាតសន្តិ |
| | បទសូត្ររម្ងាប់ហេតុអន្តរាយ |
| រចនាដោយ | ព្រះសីលវំសមហាថេរ |
| បរិវត្តដោយ | ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន |
| កាលបរិច្ឆេទ | ខែ កក្កដា ព.ស.២៥៥៦, ឆ្នាំ ២០១២ |
| សម្រាប់ | ចែកជាធម្មទាន |
| ការផ្សាយ | របស់ពុទ្ធិកបណ្ឌិតសភា |
| | នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ |
| រក្សាសិទ្ធិ | ដោយពុទ្ធិកបណ្ឌិតសភា |

Printed for free distribution by

**The Corporate Body of the Buddha Educational Foundation**

11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.

Tel: 886-2-23951198 , Fax: 886-2-23913415

Email: overseas@budaedu.org

Website:http://www.budaedu.org

Mobile Web: m.budaedu.org

**This book is strictly for free distribution, it is not to be sold.**

សម្រាប់ចែកជាធម្មទាន

## ពាក្យប្រារព្ធ

**ឧប្បាតសន្តិ** ប្រែថា មន្តរម្ងាប់ហេតុអន្តរាយ ឬបទសូធ្យរម្ងាប់ភ័យ។ ពាក្យថា **ឧប្បាត** ប្រែថា ហេតុអាក្រក់ ។ ខ្មែរហៅក្លាយថា ឧត្បាត មានន័យថា ហេតុឬភាពអាក្រក់ដែលបណ្ដាលកើតឡើងខុសពីធម្មតា, ផ្ទុលនៃគ្រោះកាច, នៃហេតុអាក្រក់, អាកេទ, ចង្រៃ, ។ **សន្តិ** ប្រែថា រម្ងាប់, ធ្វើឲ្យស្ងប់ ។ តំបន់ឡានណាហៅថា មហាសន្តិហ្ជូង ។ ជាបទសូធ្យមន្តបុរាណដែលមានប្រយោជន៍ ដើម្បីរម្ងាប់ហេតុអន្តរាយ និងសាងសន្តិសុខឲ្យកើតឡើងក្នុងភពផែនដី ។ ធម៌នេះមានគាថាសុទ្ធចំនួន ២៧១ គាថា ចាត់ជាសៀវភៅធៀងហ្មៃគន្ថៈ ឬគម្ពីរធៀងហ្មៃ មានអាយុកាលជាង ៦០០ឆ្នាំ ។

ព្រះសីលវិសុទ្ធោ ជាព្រះអរហន្ត គង់នៅក្នុងវត្តជោតិការាម ទីក្រុងធៀងហ្មៃ បានតែងឡើង តាមពាក្យអារាធនារបស់ព្រះចៅសាមហ្វាំងកែន ក្នុង ព.ស.១៩៤៩ ចុល្លសករាជ ៧៦៧ ។ សម័យនោះ មានពួកចិនលើកទ័ពមករុករានក្រុងធៀងហ្មៃ ព្រះចៅសាមហ្វាំងកែន ក៏អារាធនាសូមឲ្យព្រះថេរៈនិពន្ធបទគាថានេះឡើង ដើម្បីស្វាធ្យាយរួមគ្នាជាមួយអ្នកស្រុក បញ្ជូនផលឲ្យពួកទ័ពចិន មានភ័យវិបត្តិហើយត្រឡប់ទៅវិញ ។

គម្ពីរនេះជាបទសូធ្យសរសើរគុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃទាំងក្នុងអតីតៈ បច្ចុប្បន្ន និងអនាគត ។ ការសរសើរគុណរបស់អ្នកទ្រទ្រង់ឫទ្ធិនិងទ្រទ្រង់អំណាចផ្សេងៗ ធ្វើឲ្យកើតអានុភាពជឿថា អាចកម្ចាត់ភ័យអន្តរាយវិបត្តិផ្សេងៗ ឲ្យក្លាយទៅជាល្អវិញ ដោយអានុភាពនៃមន្តនេះ

ដែលអាងដល់គុណព្រះរតនត្រ័យ និងវត្ថុសក្តិសិទ្ធទាំងឡាយ ។ ក្នុងប្រទេសនិងសង្គមជាតិ នឹងមានតែសេចក្តីសុខ ប្រាសចាករោគភ័យ មិនមានអន្តរាយទាំងពួង និងនាំនូវគុណប្រយោជន៍ដល់អ្នកសូត្រ និងអ្នកស្តាប់ជាក់ពុំខាន ។ ក្នុងគម្ពីរសាសនវង្សប្រញ្ញាក់ថា ឧប្បាតសន្តិ អញ្ញាតកោ ថេរោ។ តំ កិរ ឧប្បាតសន្តិំ សជ្ឈាយិត្វា ចីនរញ្ញោ សេនំ អជិនីតិ ព្រះថេរៈមិនប្រាកដព្រះនាមមួយអង្គ បាននិពន្ធបករណ៍ **ឧប្បាតសន្តិ** ន័យថា សូត្រឧប្បាតសន្តិនោះឯងហើយ ធ្វើឲ្យឈ្នះទាហានចិន ។

គម្ពីរឧប្បាតសន្តិនេះ បានបោះពុម្ពផ្សាយជាច្រើនលើកច្រើនដង ក្នុងប្រទេសភូមា ដែលរាប់ជាគម្ពីរមហាសក្តិសិទ្ធិមួយ ដែលព្រះសង្ឃភូមាឲ្យឈ្មោះថា សិរីមង្គលបរិត្ត (ព្រះបរិត្តដើម្បីសិរីមង្គល) នឹងបានបោះពុម្ពផ្សាយក្នុងប្រទេសថៃ តាំងពី ព.ស.២៥០៥ ដែលបានចម្លងច្បាប់ចេញពីប្រទេសភូមា ។

គម្ពីរឧប្បាតសន្តិនេះ ជាទីនិយមសូធ្យាយក្នុងប្រទេសភូមា ដូចប្រាកដគោលស្ថានក្នុងគម្ពីរមហាសិទ្ធិ ដែលព្រះតេជគុណមហាមៈយែស្យាដ័រ រួបរួមមន្តព្រះបរិត្តផ្សេងៗ ដែលព្រះតេជគុណ ពាមែស្យាដ័រ រចនាក្នុងពុទ្ធសករាជ ២០២៤ ចុល្លសករាជ ៨៤២ ជួបថា គម្ពីរឧប្បាតសន្តិជាបទសូត្រមួយក្នុងគម្ពីរនោះ ។

រជ្ជសម័យព្រះចៅតាលួន ដែលសោយរាជ្យក្នុងពុទ្ធសករាជ ២១៧៣ ចុល្លសករាជ ៩៩១ និងរជ្ជសម័យព្រះចៅវែមបែអុិនស័ន មានរឿងក្បត់ក្នុង

ព្រះរាជវាំង មានការច្បាំងគ្នា ពួកខាងក្បត់បរាជ័យ ត្រូវសម្លាប់ចោល ។ ខាងក្រោយមក មានពួកខ្មោចដែលក្បត់មកលងបន្លាច ដោយឲ្យឃើញរូបប្លែកៗ មានទាញសំពត់ពួកស្នំជាដើម ។ ពេលខ្លះ មានសំឡេងសើច ហើយបោះផ្លែឈើ ផ្កាឈើចូលទៅខាងក្នុងព្រះរាជវាំង ។ ពេលនោះ ព្រះតេជគុណ ធម្មទន្ទ (ភូមាហៅថា ង:យ:នៃន័តសែកយងស្យាដ័រ) បានរៀបចំពិធីស្វាធ្យាយមន្តព្រះបរិត្ត ដើម្បីរម្ងាប់ហេតុអន្តរាយ ក្នុងថ្ងៃ ១២ កើត ខែ ពិសាខ ពុទ្ធសករាជ ២២១៧ ចុល្លសករាជ ១០៣៥ ។ ពង្សាវតារភូមាប្រាប់ថា គម្ពីរឧប្បាតសន្តិបានទទួលការស្វាធ្យាយជាមួយព្រះបរិត្តដទៃៗ។ បន្ទាប់ពីស្វាធ្យាយមន្តព្រះបរិត្តទាំងនេះ ខ្មោចដ៏អាក្រក់ ដែលលងនៅក្នុងព្រះរាជវាំង ក៏បាត់អស់ទៅ ។ ពេលនោះ ក្នុងប្រទេសក៏មានសេចក្ដីសុខសប្បាយ ។

កាលផ្លាស់ប្ដូរផែនដីរវាងរជ្ជសម័យព្រះចៅកចីដ័រ ជាមួយព្រះចៅតាយាវតី ក្នុងពុទ្ធសករាជ ២៣៨០ ចុល្លសករាជ ១១៩៨ មានការកើតសភាពមិនស្ងប់ក្នុងប្រទេស ។ ព្រះតេជគុណពុធ (ភូមាហៅថា យងក័នស្យាដ័រ) ប្រែឧប្បាតសន្តិឲ្យព្រះសង្ឃ ជាមួយអ្នកស្រុករួមគ្នាស្វាធ្យាយការមិនស្ងប់ក្នុងប្រទេសក៏អន្តរធានបាត់ទៅ ។

នៅក្នុងទីបញ្ចប់គម្ពីរឧប្បាតសន្តិ ព្រះសីលវំសមហាថេរ ដែលជាព្រះអរហន្ត បានចង្អុលបង្ហាញពីអានុភាពឧប្បាតសន្តិថា

ឥច្ចេវមុប្បាតសន្តឹ យោ វាចេយ្យ សុណេយ្យ វា

វិជេយ្យ សព្វថាថានិ វុទ្ធត្តញ្ច ភវិស្សតិ ។

បុគ្គលណាស្វាធ្យាយ ឬស្តាប់ឧប្បាតសន្តិ ដែលខ្ញុំពោលមក
ហើយយ៉ាងនេះ បុគ្គលនោះ គប្បីឈ្នះបាបទាំងពួង នឹងមាន
សេចក្តីចម្រើនរុងរឿង ។

សេចក្តីនេះ មានន័យថា ឱកាសដែលអកុសលឲ្យផល ជាវិបាក នោះ រមែងមិនមាន ដូចបុគ្គលខ្លះ ត្រូវអកុសលឲ្យផល ទៅជាមានអាយុខ្លី ត្រូវបាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះ លាភសក្ការៈជាដើម ។ តែកាលណា បានស្តាប់ ឬស្វាធ្យាយនូវគម្ពីរឧប្បាតសន្តិនេះ ពួកបាបអកុសលទាំងនោះ មិនមានឱកាសឲ្យផលបានឡើយ ។

សោត្ថិកាមោ លភេ សោត្ថឹ   សុខកាមោ សុខំ លភេ
អាយុកាមោ លភេយ្យាយុំ   បុត្តកាមោ លភេ បុត្តេ។

អ្នកប្រាថ្នានូវសួស្តី រមែងបាននូវសួស្តី អ្នកប្រាថ្នាសុខរមែង
បានសុខ អ្នកប្រាថ្នាអាយុ រមែងបានអាយុ អ្នកប្រាថ្នាបុត្រ
រមែងបានបុត្រ ។

ចំពោះព្រះបរិត្តដែលមានអានុភាព សម្រេចតាមសេចក្តីប្រាថ្នានោះ លុះតែបុគ្គលនោះ មានវ័យសម្បូរ មានការជឿជាក់ចំពោះព្រះបរិត្ត មិនបាន ធ្វើអនន្តរិយកម្ម មានការសម្លាប់ឪពុកបង្កើតជាដើម ។ កាលបុគ្គលប្រកប ដោយអង្គហើយ ស្តាប់ព្រះបរិត្តនេះ នឹងមានសម្រេចនូវអ្វី តាមដែលខ្លួន ប្រាថ្នា ។

ន តស្ស រោគា ពាធេន្តិ   វាតបិត្តាទិសម្ភវា
អកាលមរណំ នត្ថិ   ន ទោសា វិសមោសរេ។

*រោគកើតពីខ្យល់និងប្រមាត់ជាដើម រមែងមិនបៀតបៀន បុគ្គលនោះ សេចក្ដីស្លាប់មុនកាល រមែងមិនមាន ទេវតា មិនបៀតបៀនឲ្យធ្លាក់ចុះ ។*

ន ចុប្បាតភយំ តស្ស     នោបិ បត្តភយំ តថា
នស្សន្តិ ទុន្និមិត្តានិ     ចាបកម្មដ្ឋិតានិ ច
ទីឃមាយុ មហាសោត្ថី     អារោគ្យញ្ច សទា ភវេ ។

*ភ័យគឺហេតុអាក្រក់ រមែងមិនមាន ភ័យចំពោះមុខ នឹងមិនកើតឡើង និមិត្តអាក្រក់និងបាបគ្រោះ រមែងវិនាសទៅ ការមានអាយុវែង សិរីសួស្ដីដ៏ធំ ការមិនមានរោគ នឹងគប្បីមាន (ដល់បុគ្គលអ្នកសូធ្យាយ ឬអ្នកស្ដាប់) ។*

យោ សុត្វាបិ មហាសន្តី  សង្គាមំ បវិសេ នរោ
វិជយេ វេរិនោ សព្វេ     ន សត្ថេហ្យាភិភូយតេ ។

*បុគ្គលណាស្ដាប់ឧប្បាតសន្តិដ៏ប្រសើរហើយ គប្បីចូលទៅកាន់សង្គ្រាម នឹងឈ្នះសឹកសត្រូវ សាស្ត្រាវុធមិនអាចមុតបានឡើយ ។*

សព្វទា លភតេ បីតី     វិបត្តី នាវគាហតិ
រោគេហិ នាភិភូយតេ     សវត្ថុហិ វិវឌ្ឍតេ ។

*រមែងបានទទួលនូវបីតិសព្វៗកាល មិនមានវិបត្តិ មិនមានរោគបៀតបៀន រមែងចម្រើនដោយទ្រព្យ ។*

យត្រ ទេសេ មហោរគា   ពាឡ្ហកា រក្ខសានយោ

ឧប្បាតសន្តិយោសេន   សព្វេ តត្ថ សមន្តិ តេ ។

*ពស់ធំនិងអារក្សទឹកជាដើមដែលអាក្រក់ នៅក្នុងទីណា ទាំងអស់នោះ រមែងស្ងប់ទៅក្នុងស្ថានទីនោះ ដោយសំឡេងស្វាធ្យាយឧប្បាតសន្តិ ។*

យមុទ្ទិស្សភវេ សន្តី   សជីវញ្ចាបជីវិតំ

សោ មុច្ចតេ មហាទុក្ខា   បប្បោតិ សុគតី សទា ។

*បុគ្គលស្វាធ្យាយឧប្បាតសន្តិ ដោយឧទ្ទិសឲ្យអ្នកណា ដែលមានជីវិតរស់នៅ ឬមិនមានជីវិត រមែងរួចផុតចាកទុក្ខដ៏ធំ រមែងដល់នូវសុគតិភព ។*

ទេវដ្ឋានេ នគរេ វា   និច្ចមុប្បាតសន្តិយា

ចាលកា ទេវភាជានោ   តេជសិរិវឌ្ឍនា។

*ទេវតារក្សាទេវដ្ឋាន ឬក្នុងព្រះនគរ ជាអ្នកចម្រើនដោយតេជះនិងសិរីមង្គល ដោយឧប្បាតសន្តិ ដែលស្វាធ្យាយឧទ្ទិសឲ្យ។*

បថព្យាទាទិសញ្ជាតា   ឧប្បាតា ចន្តលិក្ខជា

ឥន្ទាទិជនិតុប្បាតា   ចាបកម្មសមុដ្ឋិតា

សព្វុប្បាតា វិនស្សន្តិ   តេជសុប្បាតសន្តិយា។

*ហេតុអាក្រក់ដែលកើតពីផែនដី និងទឹកជាដើម ដែលកើតពី*

អាកាស ដែលកើតពីចន្ទគ្រាសជាដើម ឬដែលកើតពីបាបកម្ម ហេតុអាក្រក់ទាំងអស់នោះ នឹងវិនាសទៅដោយតេជះនៃឧប្បាតសន្តិ ។

អាហារមានគុណប្រយោជន៍ សម្រាប់ឲ្យមនុស្សរស់ តែអាហារមិនអាចផ្តល់ការរស់ដល់មនុស្សគ្រប់គ្នានោះទេ យ៉ាងណា ឧប្បាតសន្តិមានគុណប្រយោជន៍ ដល់មនុស្សខ្លះ នឹងមិនមានដល់មនុស្សខ្លះ ដូចគ្នា ។

ឧប្បាតសន្តិនេះ មានគុណប្រយោជន៍ដល់ពុទ្ធសាសនិកដែលមានសទ្ធាជឿមាំក្នុងគុណព្រះរតនត្រ័យ អាចស្វាធ្យាយកម្ចាត់គ្រោះ ដែលមានឱកាលដែលនឹងឲ្យផល អាចស្វាធ្យាយលើកកាសី ជាឱកាសដែលកុសលមានកម្លាំងចេញមុខឲ្យផល ដើម្បីបានសម្រេចនូវសិរីមង្គល ។

ខ្ញុំព្រះករុណា ខ្ញុំបាទឃើញមានវិបត្តិ ឧត្បាត ហេតុអន្តរាយជាច្រើនកំពុងកើតមានក្នុងប្រទេសខ្មែរយើង ដូចជំងឺផ្តាសាយ H1N1, H1N5 និងជំងឺ Enterovirus 71 ( EV 71 ) សុទ្ធតែជំងឺកាចសាហាវ អាចបណ្តាលឲ្យមានភ័យវិបត្តិដល់សង្គមជាតិ ។ បច្ចុប្បន្នកាលនេះ ផ្កាយនក្ខត្តឫក្សទាំងឡាយ មានដំណើរមិនប្រក្រតី បណ្តាលឲ្យមានភ្លៀងជាច្រើន ខ្យល់ព្យុះ នឹងបង្កឲ្យមានទឹកជំនន់ថែមទៀត ។ ព្រះធម៌ឧប្បាតសន្តិនេះ មានអានុភាពអាចទប់ស្កាត់នូវហេតុអន្តរាយទាំងនេះបាន ឬអាចជួយកាត់បន្ថយនូវឧត្បាតនេះបានខ្លះមិនខាន ។ ខ្ញុំព្រះករុណា ខ្ញុំបាទជឿជាក់យ៉ាងមាំណាស់ ក្នុងគុណព្រះធម៌នេះថា ពិតជាមានអានុភាពដ៏ស័ក្តិសិទ្ធប្រាកដមែន ឲ្យតែសូធ្យមាន

លក្ខណៈត្រឹមត្រូវ មានពេលវេលានក្ខត្តឫក្សត្រឹមត្រូវ ប្រាកដជាអាចជួយកម្ចាត់ឧត្បាតទាំងនេះមិនខាន។

ក្នុងសម័យព្រះចៅសាមហ្វាំងកែន ដែលមានគម្ពីរឧប្បាតសន្តិនេះប្រសូតឡើងក្នុងលោក ក្នុងពុទ្ធសករាជ ១៩៤៩ ទ្រង់ឲ្យសាងមណ្ឌបតូចធំក្នុងទិសធៀងទាំង ៣ គឺ ទិសពាយព្យ បានដល់ អាយុ ទិសអគ្នេយ៍ ជាតេជៈ ទិសនិរតី ជាសិរី ។ ប្រតិស្ឋានព្រះពុទ្ធរូបក្នុងកណ្ដាលមណ្ឌបធំ និងទេវរូបព្រះឥន្ទ នៅចំខាងមុខព្រះពុទ្ធរូប ទេវរូបស្ដេចចាតុម្មហារាជិកាទាំង ៤ ស្ថិត នៅក្នុងមណ្ឌបតូចៗ ទាំង ៤ ។

ព្រះសង្ឃចាប់ស្វាធ្យាយរតនសូត្រ មេត្តសូត្រ អាដានាដិយសូត្រ មហាសមយសូត្រ និង**ឧប្បាតសន្តិ** ដោយចាប់ផ្ដើមតាំងស្ថានទី ដែលជាអាយុ ។

សម្រាប់ពិធីសូធ្យក្នុងប្រទេសខ្មែរយើងនេះ គប្បីសូធ្យតាមក្បួនមហាទក្សាចុះ ។ ក្រែងមានអ្នកមិនយល់ពីមហាទក្សា ខ្ញុំសូមលើកបង្ហាញខ្លះ ដូច្នេះ កាលណាសូធ្យសម្រាប់ប្រទេស ត្រូវយកឈ្មោះប្រទេសមកគិតឲ្យត្រូវតាមមហាទក្សា ឈ្មោះ កម្ពុជា ស្ថិតនៅចំថ្ងៃចន្ទ គឺអក្សរ ក នៅខាងដើម ត្រូវរាប់ពីនោះ ជាទក្ខិណាវដ្ដ បរិវារ អាយុ តេជៈ សិរី មូលៈ ឧស្សាហៈ មន្ត្រី កាឡកិណី ។ ដូច្នេះ ពិធីត្រូវចាប់ផ្ដើមសូធ្យពីទិសអគ្នេយ៍ ដែលជាអាយុ រហូតដល់ កាឡកិណី ។ ពិធីសូធ្យត្រូវសូធ្យចំនួន ៣ ថ្ងៃ។

# ក្បួនមហាទក្សា

ឦសាន បូព៌ អាគ្នេយ៍

| | | |
|---|---|---|
| អាទិត្យ<br>អ អា ឥ ឦ ឧ ឩ ឪ ឱ | ចន្ទ<br>ក ខ គ ឃ ង | អង្គារ<br>ច ឆ ជ ឈ ញ |
| សុក្រ<br>ស ហ ឡ | | ពុធ<br>ដ ឋ ឌ ឍ ណ |
| រាហូ (ពុធពេលយប់)<br>យ រ ល វ | ព្រហស្បតិ៍<br>ប ផ ព ភ ម | សៅរ៍<br>ត ថ ទ ធ ន |

ឧត្តរ ទក្សិណ

ពាយព្យ បស្ចិម និរតី

**សូមឧប្បាតសន្តិ ជួយបញ្ចៀសឧត្បាតឱ្យវិនាស និងនាំ**

**សិរីសួស្តីដល់មនុស្សគ្រប់គ្នា!**

ថ្ងៃទី ២២ ខែ កក្កដា ព.ស.២៥៥៦, ឆ្នាំ ២០១២

**ធម្មានន្ទ វ៉ាន់ ចាន់សារ៉េន**

អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា

ញ

# ឧប្បាតសន្តិជាធម៌ នាំមកនូវសុខសន្តិភាព!

# ឧប្បាតសន្តិ

*បទសូធ្យរម្ងាប់ឧត្បាត ឬរម្ងាប់ហេតុអន្តរាយ*

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

គន្ថារម្ភ

[ក] សុទុទ្ទសោ អយំ ធម្មោ   លោកត្ថំ ជិនទេសិតោ
មហាសន្តិករោ លោកេ   សព្វសម្បត្តិទាយកោ។

*ព្រះធម៌នេះ សត្វលោកឃើញបានដោយកម្រក្រៃលែង ព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដើម្បីប្រយោជន៍ដល់សត្វលោក ជាធម៌ធ្វើនូវមហាសន្តិ គឺសេចក្ដីស្ងប់ដ៏ធំក្នុងលោក ជាធម៌ឲ្យនូវសម្បត្តិទាំងពួង ។*

[ខ] សព្វុប្បាតូបសមណោ   ភូតយក្ខនិវារណោ
អកាលមច្ចុសមណោ   សោករោគវិនាសនោ។

*ជាធម៌រម្ងាប់ហេតុអន្តរាយទាំងពួង ជាធម៌ការពារ ពីអមនុស្ស និងយក្ស ជាធម៌ផុតពីសេចក្ដីស្លាប់ មុនកាលវេលា ជាធម៌កម្ចាត់នូវសោកនិងរោគភ័យ ។*

[គ] បរចក្កបមទ្ទនោ   រញ្ញោ វិជយវឌ្ឍនោ
សព្វានិដ្ឋហរោ សន្តោ   ធម្មំ វក្ខាមិ ភូតតោ ។

ជាធម៌ញាំញីនូវកម្លាំងរបស់សត្រូវ ជាធម៌ចម្រើន
នូវជ័យជម្នះដល់ព្រះរាជា ជាធម៌នាំវត្ថុមិនជាទីប្រាថ្នា
ចេញ ជាធម៌ដ៏ប្រសើរ ខ្ញុំនឹងពោលនូវព្រះធម៌តាម
សេចក្តីពិត ។

[ឃ] វត្ថុត្តយស្ស យោ យត្ថ សំវណ្ណោតិ គុណុត្តមេ
តស្ស តត្ថ សុខារោគ្យ- សោត្ថិយោ ហោន្តិ សព្វទា ។

ខ្ញុំនឹងពណ៌នាព្រះរតនត្រ័យណា ព្រោះគុណដ៏កំពូលណា
សេចក្តីសុខ ការមិនមានរោគ និងសេចក្តីសួស្តី រមែង
មានគ្រប់កាល ព្រោះគុណដ៏កំពូលនោះ របស់ព្រះរតនត្រ័យ
អង្គនោះ ។

# ព្រះរតនត្រ័យ

## ព្រះពុទ្ធក្នុងអតីត: ២៧ ព្រះអង្គ

## ក្នុងសារមណ្ឌកប្ប ៤ ព្រះអង្គ

[១] តណ្ហង្ករោ មហាវីរោ    សព្វលោកានុកម្បកោ

វដ្តសំសារគមនោ    សព្វកាមទទោ សទា ។

*ព្រះតណ្ហង្ករសម្មាសម្ពុទ្ធ ព្រះអង្គជាមហាវីរៈ ទ្រង់អនុគ្រោះសត្វលោកទាំងពួង ទ្រង់លះនូវការត្រាច់ទៅក្នុងសង្សារវដ្តបានហើយ សូមប្រទាននូវវត្ថុដែលគួរប្រាថ្នាទាំងពួងឲ្យ សព្វៗកាល ។*

[២] សព្វាភិភូ សព្វវិទូ    សព្វទេវគរុត្តមោ

សព្វាសវបរិក្ខីណោ    សទា សោត្ថី ករោតុ នោ ។

*ទ្រង់គ្របសង្កត់នូវធម៌ទាំងពួង ទ្រង់ដឹងច្បាស់នូវធម៌ទាំងពួង ទ្រង់ជាគ្រូដ៏កំពូលរបស់ទេវតាទាំងពួង ទ្រង់អស់អាសវៈទាំងពួងហើយ សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៣] វរលក្ខណសម្បន្នោ    មេធង្ករោ មហាមុនិ

ជុតិន្ធរោ មហាសិរី    សុវណ្ណគិរិសន្និភោ ។

ព្រះមេធង្ករសម្មាសម្ពុទ្ធ ទ្រង់ដល់ព្រមហើយដោយ
លក្ខណៈដ៏ប្រសើរ ជាព្រះមហាមុនី ទ្រង់ទ្រទ្រង់នូវ
ភាពរុងរឿង ទ្រង់មានមហាសិរី ប្រៀបដូចជាភ្នំ
នៃមាស ។

[៤] ទិព្វរូបោ មហាកាយោ    មហានាទោ មហព្ពលោ

មហាការុណិកោ សត្ថា    មហាសន្តឹ ករោតុ នោ ។

ទ្រង់ជាព្រះសាស្ដាមានព្រះរូបដូចជាទិព្វ មានព្រះមហាកាយ
ដ៏ធំ ជាទីពឹងដ៏ធំក្រៃលែង មានកម្លាំងខ្លាំងក្លា និងទ្រង់
ប្រកបដោយមហាករុណា សូមធ្វើនូវមហាសន្តិ គឺសេចក្ដី
ស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[៥] មហាមោហតមំ ហន្ត្វា    យោ នាថោ សរណង្ករោ

ទេវាទេវមនុស្សានំ    លោកានញ្ច ហិតង្ករោ ។

ព្រះសម្មាសម្ពុទ្ធអង្គឯណា ព្រះនាមសរណង្ករ ទ្រង់កម្ចាត់
នូវងងឹត គឺមោហៈដ៏ធំបានហើយ ជាទីពឹង ធ្វើនូវប្រយោជន៍
ដល់ទេវតា និងមិនមែនជាទេវតា ដល់មនុស្សនិងសត្វលោក
ទាំងឡាយ ។

[៦] ព្យាមប្បភាភិរុចិតោ    និគ្រោធបរិមណ្ឌលោ

និគ្រោធបក្កពិម្ពោដ្ឋោ    សទា សោត្ថឹ ករោតុ នោ ។

*ទ្រង់មានរស្មីមួយព្យាមដ៏រុងរឿង មានបរិមណ្ឌលដូចដើមនិគ្រោធ មានរីមព្រះឱស្ឋ ដូចផ្លែបាសទុំត្រង់ដើមនិគ្រោធ សូមព្រះសម្មាសម្ពុទ្ធអង្គនោះ ប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧] អសីតិរតនុព្វេធោ ទីបង្ករោ មហាមុនិ
បភា និច្ឆារតេ តស្ស ឋានេ ទ្វាទស យោជនេ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមទីបង្ករ មានព្រះកាយកម្ពស់ ៨០ ហត្ថ ទ្រង់ជាព្រះមហាមុនី មានរស្មីផ្សាយចេញទៅក្នុងទី ១២ យោជន៍ ។*

[៨] វស្សសតសហស្សានិ ឋត្វា លោកេ វិនាយកោ
លោកាលោកករោ សត្ថាសទា សោត្ថឹ ករោតុ នោ ។

*ទ្រង់មានព្រះជន្មនៅក្នុងលោក ១ សែនឆ្នាំ ទ្រង់ណែនាំសត្វលោក ទ្រង់ជាអ្នកធ្វើនូវពន្លឺដល់សត្វលោក ទ្រង់ជាព្រះសាស្តា សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ក្នុងសារកប្ប ១ អង្គ

[៩] អដ្ឋាសីតិហត្ថុព្វេធោ កោណ្ឌញ្ញោ នាម នាយកោ
សព្វធម្មេហិ អសមោ សព្វថារមិតាគមោ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមកោណ្ឌញ្ញៈ ទ្រង់កម្ពស់*

*៨៨ ហត្ថ ទ្រង់ជានាយក ទ្រង់ជាអ្នកមិនមានបុគ្គលណា
នីមួយស្មើដោយធម៌ទាំងពួង ទ្រង់ដល់ភាពជាអ្នកមាន
បារមីទាំងពួង ។*

[១០] វស្សសតសហស្សានិ  អាយុ តស្ស មហេសិនោ
មោចេតុ សោ សព្វភយា សទា សោត្ថី ករោតុ នោ ។

*ទ្រង់ស្វែងរកនូវគុណដ៏ធំ ទ្រង់មានព្រះជន្ម ១ សែនឆ្នាំ
សូមព្រះអង្គញុំាងខ្ញុំទាំងឡាយ ឲ្យរួចផុតចាកភ័យទាំងពួង
សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ក្នុងសារមណ្ឌកប្ប ៤ ព្រះអង្គ

[១១] អដ្ឋាសីតិរតនានិ  អច្ចុគ្គតោ ជុតិន្ធរោ
មង្គលោ នាម សម្ពុទ្ធោ  នវុតិសហស្សាយុកោ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់អង្គឯណា ព្រះនាមមង្គលៈ ទ្រង់
កម្ពស់ ៨០ ហត្ថ ទ្រង់មានអានុភាពច្រើន មានព្រះជន្ម
៩ ម៉ឺនឆ្នាំ ។*

[១២] ឆព្វណ្ណរំសិយោ ទស  សហស្សលោកធាតុយោ
ផរន្តា តស្ស ធាវេន្តិ  ឯស សោត្ថី ករោតុ នោ ។

*ឆព្វណ្ណរង្សីរបស់ព្រះអង្គ ផ្សាយទៅកាន់មួយម៉ឺនលោកធាតុ
សូមព្រះដ៏មានព្រះភាគអង្គនោះ ប្រទាននូវសួស្តីដល់ខ្ញុំ
ទាំងឡាយ សព្វៗកាល ។*

[១៣] នវុតិរតនុព្វេធោ សុមនោ នាម នាយកោ
កញ្ចនាចលសង្កាសោ នវុតិសហស្សាយុកោ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់អង្គឯណា ព្រះនាមសុមនៈ ទ្រង់កម្ពស់ ៩០ ហត្ថ ទ្រង់ជានាយក ទ្រង់ប្រៀបដូចជាភ្នំនៃមាស មានព្រះជន្ម ៩ ម៉ឺនឆ្នាំ ។*

[១៤] ឧបេតោ ពុទ្ធគុណេហិ សព្វសត្តហិតេសកោ
ករោតុ នោ មហាសន្តឹ អារោគ្យញ្ច សុខំ សទា ។

*ទ្រង់ប្រកបដោយព្រះពុទ្ធគុណទាំងឡាយ ទ្រង់ស្វែងរកនូវប្រយោជន៍ដល់សត្វលោកទាំងពួង សូមប្រទាននូវមហាសន្តិ គឺសេចក្តីស្ងប់ដ៏ធំក្រៃលែង ការមិនមានរោគ និងសេចក្តីសុខដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៥] អសីតិរតនុព្វេធោ សដ្ឋីសហស្សអាយុកោ
រេវតោ នាម សម្ពុទ្ធោ សព្វលោកុត្តរោ មុនិ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់អង្គឯណា ព្រះនាមរេវតៈ ទ្រង់កម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះជន្ម ៦ ម៉ឺនឆ្នាំ ត្រាស់ដឹងដោយព្រះអង្គឯង ប្រសើរជាងសត្វលោកទាំងពួង ជាព្រះមហាមុនី ។*

[១៦] តស្ស សរីរេ និព្វត្តា បភាមាលា អនុត្តរា
ជាលា យោជនេ និច្ចំ សទា សោត្ថឹ ករោតុ នោ ។

*កម្រងរស្មីដ៏ប្រសើរខ្ពង់ខ្ពស់ ផ្សាយទៅក្នុង ១ យោជន៍*
*អស់កាលជានិច្ច ដែលកើតហើយក្នុងសរីរៈរបស់ព្រះអង្គ*
*សូមប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៧] សោភិតោ នាម សម្ពុទ្ធោ នវុតិសហស្សាយុកោ
សំសារសាគរេ សត្តេ ពហូ មោចេតិ ទុក្ខតោ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមសោភិតៈ ទ្រង់មាន*
*ព្រះជន្ម ៩ ម៉ឺនឆ្នាំ ទ្រង់ញ៉ាំងសត្វលោកជាច្រើន ឲ្យ*
*រួចចាកទុក្ខក្នុងសាគរ គឺសង្សារវដ្ត ។*

[១៨] អដ្ឋបញ្ញាសរតនំ អច្ចុគ្គតោ មហាមុនិ
ឱភាសេតិ ទិសា សព្វា សទា សោត្ថិ ករោតុ នោ ។

*ទ្រង់កម្ពស់ ៥៨ ហត្ថ ជាព្រះមហាមុនី ទ្រង់ញ៉ាំងទិស*
*ទាំងពួងឲ្យភ្លឺស្វាង សូមប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ*
*សព្វៗកាល ។*

## ក្នុងវរកប្ប ៣ ព្រះអង្គ

[១៩] អនោមទស្សី សម្ពុទ្ធោ តេជសី ទុរតិក្កមោ
អដ្ឋបញ្ញាសរតនោ ឱភាសេន្តោ សទេវកេ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមអនោមទស្សី ទ្រង់*

មានតេជះ ដែលអ្នកណានីមួយ មិនអាចកន្លងបាន ទ្រង់កម្ពស់ ៥៨ ហត្ថ ទ្រង់ញុំាងមនុស្ស ព្រមទាំងទេវតា ឲ្យភ្លឺស្វាង ។

[២០] និព្វានទាយកោ លោកេ វស្សសតសហស្សាយុ
ករោតុ នោ មហាសន្តឹ សុខិតា ច មយំ សទា ។

ទ្រង់រំលត់នូវបាបធម៌ហើយក្នុងលោក ទ្រង់មានព្រះជន្ម ១ សែនឆ្នាំ សូមប្រទាននូវមហាសន្តិ គឺសេចក្តីស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ និងខ្ញុំទាំងឡាយ ចូរជាអ្នកបាននូវសេចក្តីសុខ សព្វៗកាល ។

[២១] បទុមោ នាម សម្ពុទ្ធោ លោកជេដ្ឋោ នរាសភោ
អដ្ឋបញ្ញាសរតនោ អាទិច្ចោវ វិរោចតិ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមបទុមៈ ទ្រង់ជាចម្បងក្នុងលោក ជានរៈដ៏ប្រសើរ ទ្រង់កម្ពស់ ៥៨ ហត្ថ រុងរឿងដូចជាព្រះអាទិត្យ ។

[២២] វស្សសតសហស្សានិ អាយុ តស្ស មហេសិនោ
សោបិ ពុទ្ធោ ការុណិកោ សទា សោត្ថឹ ករោតុ នោ ។

ទ្រង់ស្វែងរកនូវគុណដ៏ធំ ទ្រង់មានព្រះជន្ម ១ សែនឆ្នាំ ព្រះពុទ្ធជាម្ចាស់ សូម្បីអង្គនោះ ទ្រង់ប្រកបដោយករុណា សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២៣] អដ្ឋាសីតិរតនុព្វេធោ  នារទោ សព្វកាមទោ
និរន្តរំ ទិវារត្តឹ  យោជនំ ផរតេ បភា ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមនារទៈ ទ្រង់កម្ពស់ ៨៨ ហត្ថ ទ្រង់ប្រទាននូវវត្ថុដែលគួរពេញចិត្តទាំងពួង រស្មីរបស់ព្រះអង្គ ផ្សាយចេញទៅ ១ យោជន៍ទាំងថ្ងៃ ទាំងយប់ អស់កាលជានិច្ច ។*

[២៤] នវុតិវស្សសហស្សានិ  ឋត្វា លោកេ វិនាយកោ
មោចេតិ ទុក្ខតោ សត្តេ  សោបិ សោត្ថឹ ករោតុ នោ ។

*ទ្រង់ណែនាំសត្វលោក ទ្រទ្រង់ព្រះជន្មក្នុងលោក រហូត ៩ ម៉ឺនឆ្នាំ ទ្រង់ញ៉ាំងសត្វលោកទាំងឡាយឲ្យរួចផុតចាក ទុក្ខ សូម្បីព្រះពុទ្ធជាម្ចាស់អង្គនោះ សូមប្រទាននូវសួស្តី ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ក្នុងសារកប្ប ១ ព្រះអង្គ

[២៥] អដ្ឋបញ្ញាសរតនោ  បទុមុត្តរោ មហាមុនិ
តស្ស ចាកតិនា រំសី  ផរន្តិ ទ្វាទសយោជនេ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមបទុមុត្តរៈ ទ្រង់កម្ពស់ ៥៨ ហត្ថ ទ្រង់ជាមហាមុនី រស្មីមានដោយប្រក្រតីរបស់ ព្រះអង្គ ផ្សាយទៅក្នុងទី ១២ យោជន៍ ។*

[២៦] វស្សសតសហស្សានិ ឋត្វា លោកេមតន្ទទោ
មោចេតិ ពន្ធនា សត្តេ សោបិ ចាលេតុ នោ សទា ។
*ទ្រង់ប្រទានអមតៈ គឺព្រះនិព្វាន ទ្រង់ទ្រទ្រង់ព្រះជន្មក្នុងលោក រហូត ១ សែនឆ្នាំ ទ្រង់ញ៉ាំងសត្វទាំងឡាយឲ្យរួចផុតចាក កិលេសជាគ្រឿងចង សូមព្រះពុទ្ធជាម្ចាស់អង្គនោះ សូមប្រទាននូវការរក្សាដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

## ក្នុងមណ្ឌកប្ប ២ ព្រះអង្គ

[២៧] អដ្ឋាសីតិរតនានិ អច្ចុគ្គតោ មហាមុនិ
សុមេធោ នាម សម្ពុទ្ធោ នវុតិសហស្សាយុកោ ។
*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមសុមេធៈ មានព្រះកាយ កម្ពស់៨៨ ហត្ថ ទ្រង់ជាមុនីដ៏ប្រសើរ មានព្រះជន្ម ៩ ម៉ឺនឆ្នាំ។*

[២៨] តស្ស ចាកតិកា រំសី ផរន្តិ យោជនំ សទា
ចាលេតុ នោ សទា ពុទ្ធោ ភយេហិ វិវិធេហិ ច ។
*ព្រះរស្មីមានតាមប្រក្រតីរបស់ព្រះអង្គ ផ្សាយទៅរហូត មួយម៉ឺនយោជន៍ សូមព្រះពុទ្ធជាម្ចាស់អង្គនោះ ធ្វើ នូវការរក្សាដល់ខ្ញុំទាំងឡាយ ឲ្យរួចផុតចាកភ័យវិបត្តិ មានប្រការផ្សេងៗ ។*

[២៩] បញ្ញាសរតនុព្វេធោ សុជាតោ នាម នាយកោ
ហេមវណ្ណោ មហាវីរោ មហាតមវិនោទនោ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម សុជាតៈ មានព្រះកាយកម្ពស់ ៥០ ហត្ថ ទ្រង់មានព្រះឆវីវណ្ណដូចជាមាស ទ្រង់ក្បៀវក្លា យ៉ាងក្រៃលែង ទ្រង់បន្ទោបង់នូវងងឹតដ៏ធំ គឺមោហៈ ។*

[៣០] នវុតិវស្សសហស្សានិ អាយុ តស្ស មហេសិនោ
សោបិ ពុទ្ធោ ការុណិកោ សទា សោត្ថី ករោតុ នោ ។

*ទ្រង់មានព្រះជន្ម ៩ ម៉ឺនឆ្នាំ សូម្បីព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់មានករុណា សូមប្រទាននូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល ។*

## ភ្លូខទរភប្ប ៣ ព្រះអង្គ

[៣១] អសីតិរតនុព្វេធោ បិយទស្សី មហាមុនិ
នវុតិវស្សសហស្សានិ ឋត្វា លោកគ្គនាយកោ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម បិយទស្សី មានព្រះកាយកម្ពស់ ៨០ ហត្ថ ទ្រង់ជាមុនីដ៏ប្រសើរ ទ្រង់ជានាយកដ៏កំពូលក្នុង លោក ទ្រង់មានព្រះជន្ម ៩ ម៉ឺនឆ្នាំ ។*

[៣២] សោបិ សព្វគុណូបេតោ សព្វលោកសុខប្បទោ
សព្វទោសំ វិនាសេន្តោ សព្វំ សោត្ថី ករោតុ នោ ។

*សូម្បីព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់ប្រកបដោយគុណ ទាំងពួង ប្រទាននូវសេចក្តីសុខដល់សត្វលោកទាំងមូល*

ទ្រង់កម្ចាត់ទោសទាំងអស់ សូមប្រទាននូវសួស្តីដល់ខ្ញុំ
ទាំងឡាយ សព្វៗកាល ។

[៣៣] អសីតិរតនុព្វេធោ អត្ថទស្សី នរាសភោ
វស្សសតសហស្សានិ លោកេ អដ្ឋាសិ នាយកោ ។

ព្រះពុទ្ធជាម្ចាស់ ព្រះនាម អត្ថទស្សី មានព្រះកាយកម្ពស់
៨០ ហត្ថ ទ្រង់ជានរៈដ៏ប្រសើរ ទ្រង់មានព្រះជន្មក្នុងលោក
១ សែនឆ្នាំ ។

[៣៤] តស្ស ចាកតិកា រំសី ផរន្តិ យោជនំ សទា
និរន្តរំ ទិវារត្តឹ នាថោ សោត្ថឹ ករោតុ នោ ។

ព្រះរស្មីតាមប្រក្រតីរបស់ព្រះអង្គ ផ្សាយទៅអស់មួយ
យោជន៍ ទាំងយប់ទាំងថ្ងៃអស់កាលជានិច្ច ព្រះអង្គជា
ទីពឹងនៃសត្វលោក សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ
សព្វៗកាល ។

[៣៥] ធម្មទស្សី ច សម្ពុទ្ធោ អសីតិហត្ថមុគ្គតោ
អតិរោចតិ តេជេន សទេវាសុរមានុសេ ។

ព្រះពុទ្ធជាម្ចាស់ ព្រះនាម ធម្មទស្សី មានព្រះកាយកម្ពស់
៨០ ហត្ថ ទ្រង់រុងរឿងលើសព្រហ្ម ទេវតា អសុរ និង
មនុស្សទាំងឡាយ ដោយតេជានុភាព ។

[៣៦] វស្សសតសហស្សានិ ឋត្វា លោកេ មហាយសោ
សព្វសត្តេ បមោចេតិ ភយា រក្ខតុ នោ សទា ។

*ទ្រង់មានយសដ៏ធំ មានព្រះជន្មក្នុងលោក ១ សែនឆ្នាំ ទ្រង់ញុំាងសត្វឲ្យរួចចាកភ័យ សូមរក្សានូវខ្ញុំទាំងឡាយ ឲ្យរួចផុតចាកភ័យ សព្វៗកាល ។*

**ក្នុងសារកប្ប ១ ព្រះអង្គ**

[៣៧] សិទ្ធត្ថោ នាម សម្ពុទ្ធោ សដ្ឋិរតនមុគ្គតោ
តិភវេ សោត្ថិជនកោ សតសហស្សអាយុកោ ។

*ព្រះសម្ពុទ្ធជាម្ចាស់ ព្រះនាម សិទ្ធត្ថៈ មានព្រះកាយកម្ពស់ ៦០ ហត្ថ ទ្រង់ញុំាងសួស្តីឲ្យកើតឡើងក្នុងភពទាំងបី មាន ព្រះជន្ម ១ សែនឆ្នាំ ។*

[៣៨] សំសារសាគរា លោកេ សន្តារេត្វា សទេវកេ
និព្វាបេសិ ច សោ សត្ថា សទា សោត្ថឹ ករោតុ នោ ។

*ទ្រង់ញុំាងមនុស្សនិងទេវតា ឲ្យឆ្លងចាកសាគរនៃសំសារវដ្ត និងឲ្យរំលត់កិលេស សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ក្នុងមណ្ឌកប្ប ២ ព្រះអង្គ

[៣៩] សព្វិរតនម្ពុត្រោ  តិស្សោ លោកគ្គនាយកោ

អនូបមោ អសទិសោ  អតុលោ ឧត្តមោ ជិនោ ។

*ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រសើរក្នុងលោក ព្រះនាម តិស្សៈ មានព្រះកាយកម្ពស់ ៦០ ហត្ថ ទ្រង់ជាព្រះជិនស្រី ដ៏ឧត្តម មិនមានបុគ្គលដទៃប្រៀបប្រដូចបាន មិនមានអ្នកស្មើ មានព្រះគុណមិនអាចថ្លឹងថ្លៃងបាន ។*

[៤០] វស្សសតសហស្សានិ  អាយុ តស្ស មហេសិនោ

អារោគ្យញ្ច មហាសុខំ  ហោតុ នោ តស្ស តេជសា ។

*ទ្រង់មានព្រះជន្ម ១ សែនឆ្នាំ ដោយតេជះរបស់ព្រះអង្គ សូមសុខភាពល្អនិងសេចក្តីសុខដ៏ធំក្រៃលែង ចូរមានដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[៤១] អដ្ឋបញ្ញាសរតនោ  បុស្សោ លោកគ្គនាយកោ

ជនម្ពុជំ វិពោធេន្តោ  និព្វាបេន្តោ សទេវកេ ។

*ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រសើរក្នុងលោក ព្រះនាម បុស្សៈ មានព្រះកាយកម្ពស់ ៥៨ ហត្ថ ទ្រង់ញ៉ាំងបទុមជាតិគឺវេនេយ្យសត្វឲ្យរីក ទ្រង់ញ៉ាំងមនុស្សនិងទេវតាឲ្យរំលត់ទុក្ខ។*

[៤២] នវុតិវស្សសហស្សានិ ឋត្វា លោកេ មហាយសោ
ឧទ្ធរន្តោ ពហូ សត្តេ សទា សោត្ថឹ ករោតុ នោ ។
*ទ្រង់មានយសដ៏ធំ ទ្រទ្រង់ព្រះជន្មក្នុងលោក ៩ ម៉ឺនឆ្នាំ ទ្រង់ញ៉ាំងសត្វដ៏ច្រើន ឲ្យចេញចាកវដ្តៈ សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ក្នុងសារកប្ប ១ ព្រះអង្គ

[៤៣] អសីតិរតនុព្វេធោ វិបស្សី លោកនាយកោ
បភា និទ្ធាវតេ តស្ស សមន្តា សត្តយោជនេ ។
*ព្រះពុទ្ធជាម្ចាស់ ព្រះនាម វិបស្សី មានព្រះកាយកម្ពស់ ៨០ហត្ថ ព្រះរស្មីរបស់ព្រះអង្គ ផ្សាយទៅ ៧ យោជន៍ ដោយជុំវិញអស់កាលជានិច្ច ។*

[៤៤] សោបិ ទេវមនុស្សានំ ពន្ធនា បរិមោចយិ
អសីតិសហស្សាយុកោ នាថោ សោត្ថឹ ករោតុ នោ ។
*ទ្រង់មានព្រះជន្ម ៨ ម៉ឺនឆ្នាំ ទ្រង់ញ៉ាំងទេវតានិងមនុស្សទាំងឡាយ ឲ្យរួចចាកគ្រឿងចំណង គឺកិលេស សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ក្នុងមណ្ឌកប្ប ២ ព្រះអង្គ

[៤៥] សត្តតិហត្ថមុព្វេធោ សិខី នាមេស នាយកោ
បភា និទ្ធាវតេ តស្ស សមន្តា យោជនត្តយេ ។

ព្រះពុទ្ធជាម្ចាស់ ព្រះនាម សិខី មានព្រះកាយកម្ពស់
៧០ ហត្ថ ព្រះរស្មីរបស់ព្រះអង្គ ផ្សាយទៅ ៣ យោជន៍
ដោយជុំវិញអស់កាលជានិច្ច ។

[៤៦] សោបិ អតុលោ្យ សម្ពុទ្ធោ សត្តតិសហស្សាយុកោ
កករោតុ នោ មហាសន្តឹ សុខិតា ច មយំ សទា ។

ព្រះសម្ពុទ្ធជាម្ចាស់អង្គនោះ មានព្រះគុណមិនអាចថ្លឹងថ្លែង
បាន មានព្រះជន្ម ៧ ម៉ឺនឆ្នាំ សូមប្រទាននូវសេចក្ដីស្ងប់ដ៏ធំ
ក្រៃលែងដល់ខ្ញុំទាំងឡាយ និងខ្ញុំទាំងឡាយ ចូរជាអ្នកមាន
សេចក្ដីសុខ សព្វៗកាល ។

[៤៧] វេស្សភូ នាម សម្ពុទ្ធោ ហេមរូបសមូបមោ
សដ្ឋិរតនមុព្វេធោ សដ្ឋិ ច សហស្សាយុកោ ។

ព្រះពុទ្ធជាម្ចាស់ ព្រះនាម វេស្សភូ ទ្រង់ឆវីវណ្ណដូចជាមាស
មានព្រះកាយកម្ពស់ ៦០ ហត្ថ មានព្រះជន្ម ៩ ម៉ឺនឆ្នាំ ។

[៤៨] ព្រហ្មទេវមនុស្សេហិ នាគាសុរេហិនេហិ វា
បូជិតោបិ សទា នាថោ សទា សោត្ថឹ ករោតុ នោ ។

ព្រះអង្គជាទីពឹង ដែលព្រហ្ម ទេវតា មនុស្ស នាគ អសុរ
និងគ្រុឌបូជាហើយ សូមព្រះអង្គប្រទាននូវសួស្ដីដល់ខ្ញុំទាំង
ឡាយ សព្វៗកាល ។

## ក្នុងភទ្ទកប្ប ៥ ព្រះអង្គ
## កន្លងទៅហើយ ៣ ព្រះអង្គ

[៤៩] តាឡីសរតនុព្វេធោ កកុសន្ធោ មហាមុនិ
តស្ស កាយា និច្ឆរន្តិ បភា ទ្វាទសយោជនេ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម កកុសន្ធៈ ទ្រង់ជាមុនី មាន
ព្រះកាយកម្ពស់ ៤០ ហត្ថ ព្រះរស្មីរបស់ព្រះអង្គ
ផ្សាយទៅ ១២ យោជន៍អស់កាលជានិច្ច ។*

[៥០] ចត្តាឡីសសហស្សានិ តស្ស អាយុ អនុត្តរោ
ករោតុ សោ សទា នាថោ អាយុំ សុខំ ពលញ្ច នោ ។

*ទ្រង់មានព្រះជន្ម ៤ ម៉ឺនឆ្នាំ ទ្រង់ជាទីពឹងដ៏ប្រសើរ
សូមប្រទាននូវអាយុ សេចក្តីសុខ និងកម្លាំងដល់
ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៥១] កោណាគមនសម្ពុទ្ធោ តឹសហត្ថសមុគ្គតោ
តឹសវស្សសហស្សានិ អាយុ តស្ស មហេសិនោ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម កោណាគមនៈ មានព្រះកាយ
កម្ពស់ ៣០ ហត្ថ ទ្រង់មានព្រះជន្ម ៣ ម៉ឺនឆ្នាំ ។*

[៥២] ធម្មាមតេន តប្បេតា ទេវសង្ឃំ សុរាលយេ
មហីតលេ ច ជនតំ សទា សោត្ថី ករោតុ នោ ។

*ព្រះអង្គទ្រង់ញ៉ាំងទេពក្នុងសុរាល័យ និងពួកជនក្នុងប្រឹថពី*

*ឲ្យឆ្អែតដោយអមតធម៌ សូមព្រះអង្គប្រទានទូវសួស្តីដល់ ខ្ញុំទាំងឡាយអស់កាលជានិច្ច ។*

[៨៣] កស្សបោ នាម សម្ពុទ្ធោ ធម្មរាជា បភង្ករោ
វីសតិហត្ថមុព្វេធោ វីសសហស្សអាយុកោ ។

*ព្រះសម្ពុទ្ធជាម្ចាស់ ព្រះនាម កស្សបៈ ទ្រង់ជាធម្មរាជា ទ្រង់មានរស្មី មានព្រះកាយកម្ពស់ ២០ ហត្ថ មាន ព្រះជន្ម ២ ម៉ឺនឆ្នាំ ។*

[៨៤] អនូបមោសមសមោ ទេវសត្ថា អនុត្តរោ
ករោតុ នោ មហាសន្តឹ អារោគ្យញ្ច ជយំ សទា ។

*ទ្រង់មិនមានអ្នកស្មើ ទ្រង់ស្មើនឹងព្រះពុទ្ធអង្គមុនដ៏ប្រសើរ ទ្រង់ជាសាស្តារបស់ពួកទេពទាំងឡាយ សូមព្រះអង្គ ប្រទានទូវសេចក្តីស្ងប់ដ៏ធំ សុខភាពល្អ និងជ័យជម្នះ ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ព្រះពុទ្ធក្នុងបច្ចុប្បន្ន ១ ព្រះអង្គ

[៨៥] អដ្ឋារសហត្ថុព្វេធោ គោតមោ សក្យវឌ្ឍនោ
សព្វញ្ញូ សព្វតិលកោ សព្វលោកសុខប្បទោ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម គោតម មានព្រះកាយកម្ពស់ ១៨ ហត្ថ ទ្រង់ជាអ្នកចម្រើនក្នុងសក្យវង្ស ទ្រង់ជា*

សព្វញ្ញូ ទ្រង់ប្រៀបដូចតិលកនៃត្រៃលោកទាំងពួង
ទ្រង់ជាអ្នកប្រទាននូវសេចក្ដីសុខដល់សត្វលោកទាំងពួង ។

[៨៦] សម្ពុទ្ធោ សព្វធម្មានំ ភគេហិ ភាគ្យវាយុកោ
វិជ្ជាចរណសម្បន្នោ សោត្ថ្យាភាគ្យំ ទទាតុ នោ ។

ទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួងដោយព្រះអង្គឯង ទ្រង់បរិបូណ៌
ដោយបុញ្ញាកិនិហារ មានព្រះបារមីដ៏ខ្ពង់ខ្ពស់ ទ្រង់បរិបូណ៌
ដោយវិជ្ជានិងចរណៈ សូមព្រះអង្គប្រទាននូវសួស្ដីនិង
សុខភាពល្អដល់ខ្ញុំទាំងឡាយ ។

[៨៧] អព្ភាតីតា ច សម្ពុទ្ធា អនេកសតកោដិយោ
សព្វលោកមភិញ្ញាយ សព្វសត្តានុកម្បិនោ ។

ម្យ៉ាងទៀត ព្រះពុទ្ធទាំងឡាយច្រើនរយកោដិ ដែលកន្លង
ទៅហើយ ទ្រង់ដឹងប្រចក្សនូវលោកទាំងពួងហើយ ទ្រង់
អនុគ្រោះសត្វលោកទាំងពួង ។

[៨៨] សព្វវេរភយាតីតា សព្វលោកសុខប្បទា
សព្វទោសំ វិនាសេន្តា សព្វសោត្ថឹ ករោតុ នោ ។

ទ្រង់កន្លងផុតចាកពៀរនិងភ័យ ទ្រង់ប្រទាននូវសេចក្ដីសុខ
ដល់សត្វលោកទាំងពួង ទ្រង់កម្ចាត់ទោសទាំងអស់
សូមព្រះអង្គប្រទាននូវសួស្ដីគ្រប់ប្រការដល់ខ្ញុំទាំងឡាយ។

## ព្រះពុទ្ធក្នុងអនាគត ១ ព្រះអង្គ

[៥៩] អនាគតេ ច សម្ពុទ្ធោ មេត្តេយ្យោ ទេវបូជិតោ
មហិទ្ធិកោ មហាទេវោ មហាសន្តឹ ករោតុ នោ ។

*ម្យ៉ាងទៀត ក្នុងអនាគត ព្រះសម្ពុទ្ធ ព្រះនាម មេត្រី ដែលពួកទេពបូជាហើយ ទ្រង់មានឫទ្ធិច្រើន ទ្រង់ជា មហាទេព សូមព្រះអង្គប្រទាននូវសេចក្តីស្ងប់ដ៏ធំ ដល់ខ្ញុំទាំងឡាយ។*

## ព្រះបច្ចេកពុទ្ធ

[៦០] សព្វេ បច្ចេកសម្ពុទ្ធា និរោធឈានកោវិទា
និរាលយា និរាសង្កា អប្បមេយ្យា មហោសយោ ។

*ព្រះបច្ចេកពុទ្ធទាំងឡាយទាំងពួង ទ្រង់ជំនាញក្នុងនិរោធ និងឈាន ទ្រង់ប្រាសចាកតណ្ហា និងសេចក្តីញាប់ញ័រ ទ្រទ្រង់គុណរកប្រមាណមិនបាន ស្វែងរកនូវគុណដ៏ធំ ។*

[៦១] ទូរេបិ វិនេយ្យា ទិស្វា សម្បត្តា តង្ខណេន តេ
សន្និដ្ឋិកជលេ កត្វា សទា សន្តឹ ករោតុ នោ ។

*ទ្រង់សំឡឹងឃើញវេនេយ្យជន សូម្បីក្នុងទីឆ្ងាយ ក៏និមន្តទៅ ប្រោសជនទាំងនោះ ឲ្យបានទទួលនូវប្រយោជន៍ក្នុងបច្ចុប្បន្ន ដោយរហ័សក្លាម សូមព្រះអង្គប្រទាននូវសេចក្តីស្ងប់ដល់ខ្ញុំ ទាំងឡាយ។*

## ព្រះធម៌

[៦២] ស្វាក្ខាតាទិសម្បន្នោ ធម្មោ សបរិយត្តិកោ
សំសារសាគរា លោកេ តារេតិ ជិនគោចរោ ។

*ព្រះធម៌ ព្រមទាំងព្រះបរិយត្តិ ដែលបរិបូណ៌ដោយគុណ មានភាពជាធម៌ដែលព្រះពុទ្ធទ្រង់ត្រាស់សម្ដែងល្អហើយ ដែលជាអារម្មណ៍របស់ព្រះពុទ្ធ រមែងញុំាងសត្វលោក ឲ្យឆ្លងចាកសាគរនៃសំសារវដ្ត ។*

[៦៣] កិលេសជាលវិទ្ធំសី វិសុទ្ធោ ពុទ្ធសេវិតោ
និព្វានគមនោ សន្តោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះធម៌ដ៏បរិសុទ្ធក្រៃលែង ដែលទម្លាយសំណាញ់គឺ កិលេស ជាធម៌ដែលព្រះពុទ្ធជាម្ចាស់ចម្រើនហើយ ជា ធម៌ដ៏ស្ងប់ឲ្យទម្លុះព្រះនិព្វាន ចូរប្រទាននូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល ។*

## ព្រះសង្ឃ

[៦៤] សីលាទិគុណសម្បន្នោ សង្ឃោ មគ្គផលេ ឋិតោ
ជិតិន្ទ្រិយោ ជិតចាចោ ទក្ខិណេយ្យោ អនុត្តរោ។

*ព្រះសង្ឃអ្នកបរិបូណ៌ដោយគុណមានសីលជាដើម ទ្រទ្រង់ នូវមគ្គផល ជាអ្នកឈ្នះឥន្ទ្រិយ និងបាបបាន ជាអ្នកគួរ ទទួលនូវទក្ខិណាដ៏ប្រសើរ ។*

[៦៥] អនាសវោ បរិសុទ្ធោ   និរាសាសោ ភវាភវេ

និព្វានគោចរោ សន្តោ   សទា សោត្ថឹ ករោតុ នោ ។

*ជាអ្នកប្រាសចាកអាសវៈ ជាអ្នកបរិសុទ្ធ ផុតចាកសេចក្តីប្រាថ្នាក្នុងភពតូចនិងភពធំ ជាអ្នកស្ងប់ មានព្រះនិព្វានជាអារម្មណ៍ សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយសព្វៗកាល។*

**ព្រះមហាថេរៈ ១៨២ អង្គ**

[៦៦] អញ្ញាតកោណ្ឌញ្ញត្ថេរោ   រត្តញ្ញូនំ អគ្គោ អហុ

ធម្មចក្កាភិសមយោ   សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះអញ្ញាកោណ្ឌញ្ញៈ ជាអ្នកកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានរាត្រីយូរ ជាអ្នកទម្លុះសោតាបន្ន ដោយ(ការស្តាប់) ធម្មចក្កប្បវត្តនសូត្រ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៦៧] វប្បត្ថេរោ មហាបញ្ញោ   មហាតមវិនោទនោ

មហាសន្តិករោ លោកេ   មហាសន្តឹ ករោតុ នោ ។

*សូមព្រះវប្បត្ថេរ ជាអ្នកមានបញ្ញាច្រើន ជាអ្នកកម្ចាត់នូវងងឹតដ៏ធំ គឺមោហៈ ជាអ្នកប្រទាននូវស្ងប់ដ៏ធំក្នុងលោក ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ។*

[៦៨] ភទ្ទិយោ ភទ្ទសីលោ ច   ឧក្កិឈោយ្យោ អនុត្តរោ

លោកត្ថចរិតោ ថេរោ   សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះភទ្ទិយត្ថេរ អ្នកមានសីលដ៏ល្អ គួរទទួលនូវទក្ខិណា ដ៏ប្រសើរ ជាអ្នកបំពេញនូវប្រយោជន៍ដល់សត្វលោក ចូរ ប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[៦៩] មហានាមោ មហាបញ្ញោ មហាធម្មវិទូ សុតោ
មហាខីណាសវោ ថេរោ មហាសន្តឹ ករោតុ នោ ។

*សូមព្រះមហានាមត្ថេរ ជាអ្នកមានបញ្ញាច្រើន ជាអ្នកត្រាស់ ដឹងនូវធម៌ដ៏ប្រសើរ មានព្រះនាមរន្ទឺ ជាព្រះមហាខីណាស្រព ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧០] អស្សជិតថេរោ មហាបញ្ញោ ជិតមារោ ជិតិន្ទ្រិយោ
ជិតបច្ចត្ថិកោ លោកេ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះអស្សជិតត្ថេរ ជាអ្នកមានបញ្ញាច្រើន ជាអ្នកឈ្នះមារ ជាអ្នកឈ្នះឥន្ទ្រិយ ជាអ្នកឈ្នះសត្រូវក្នុងលោក ចូរប្រទាន នូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧១] អនុបុព្វិកថំ សុត្វា យសោ ឯកគ្គមានសោ
អគ្គធម្មមនុប្បត្តោ សោត្ថ្យារោគ្យំ ទទាតុ នោ ។

*សូមព្រះយសត្ថេរ ជាអ្នកស្តាប់អនុបុព្វីកថាហើយ មានចិត្ត មាំ បានទម្លុះនូវធម៌ប្រសើរ (គឺអរហត្តផល) ចូរប្រទាននូវ សួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ ។*

[៧២] ចត្វាធិកា ច បញ្ញាស ថេរា គិហិសហាយកា
បត្វាន បរមំ សន្តឹ សទា សោត្ថឹ ករោន្តុ នោ ។

និងព្រះមហាថេរៈជាព្រះអរហន្ត ៥៤ អង្គ ជាប់ជាសម្លាញ់ របស់ព្រះយសត្ថេរ កាលនៅជាគ្រហស្ថ បានទម្លុះព្រះនិព្វាន ដ៏ប្រសើរហើយ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗ កាល ។

[៧៣] យេ តឹស ភទ្ទវគ្គិយា រូបេនាតុលវណ្ណិនោ
ខីណាសវា វសីភូតា តេ ករោន្តុ អនាមយំ ។

ព្រះភទ្ទវគ្គិយៈ ៣០ អង្គណា ជាអ្នកមានរូបសម្បុរមិនមាន អ្នកស្មើ អស់អាសវៈហើយ ជាអ្នកឈ្នះខ្លួន ជំនាញក្នុង សមាបត្តិ (គឺឈានសមាបត្តិ ផលសមាបត្តិ និងនិរោធ សមាបត្តិ) សូមប្រទាននូវសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[៧៤] ឧរុវេលកស្សបោបិ មហាបរិសានមុត្តមោ
ឋបិតោ អគ្គឋានម្ហិ សទា សោត្ថឹ ករោតុ នោ ។

សូមព្រះឧរុវេលកស្សបត្ថេរ ជាអ្នកទ្រទ្រង់តំណែងកំពូល ជាងភិក្ខុទាំងឡាយ អ្នកមានបរិស័ទច្រើន ចូរប្រទាននូវ នូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[៧៥] យោ នទីកស្សបត្ថេរោ    បុញ្ញក្ខេត្តោ អនុត្តរោ
សសង្ឃោ សីលសម្បន្នោ សទា សោត្ថឹ ករោតុ នោ។

*សូមព្រះនទីកស្សបត្ថេរ ជាអ្នកមានបុណ្យដ៏ប្រសើរ ជាអ្នកមានសង្ឃជាបរិវារ សម្បូរដោយសីល ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧៦] ធម្មបជ្ជលិតោ សន្តោ    យោ ថេរោ គយាកស្សបោ
សំយុត្តោ ភវនិស្នេហោ    សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះគយាកស្សបត្ថេរ ជាអ្នករុងរឿងដោយធម៌ ជាអ្នកស្ងប់ដ៏កំពូលក្នុងត្រៃភព ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧៧] លោកនាថំ ឋបេត្វាន    បញ្ញវន្តាន ចាណិនំ
បញ្ញាយ សារិបុត្តស្ស    កលំ នាគ្ឃតិ សោឡសឹ ។

*បណ្តាអ្នកមានបញ្ញាទាំងឡាយ វៀរលែងតែព្រះជាពុទ្ធជាម្ចាស់ ដែលជាទីពឹងនៃសត្វលោកហើយ បុគ្គលណាៗរមែងមិនដល់ចំណែកទី ១៦ នៃបញ្ញារបស់ព្រះសារីបុត្រ ។*

[៧៨] សារិបុត្តោ មហាបញ្ញោ    បឋមោអគ្គសាវកោ
ធម្មសេនាបតី សេដ្ឋោ    សទា សោត្ថឹ ករោតុ នោ ។

សូមព្រះសារីបុត្រអ្នកមានបញ្ញាច្រើន ជាអគ្គសាវកទីមួយ ជាព្រះធម្មសេនាបតីដ៏ប្រសើរ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[៧៩] ចានង្គុលិកមត្តេន    វេជយន្តបកម្បនោ

បឋវឹ មហាតឹ សព្វំ    សមត្ថោ បរិវត្តិតុំ ។

ព្រះមហាថេរៈអង្គណា អាចញ៉ាំងប្រាសាទវេជយន្តឲ្យកម្រើកញាប់ញ័រ ដោយត្រឹមមេជើង អាចត្រឡប់នូវមហាប្រឹថពីបានទាំងអស់ ។

[៨០] មោគ្គល្លានោ មហាថេរោ ទុតិយោ អគ្គសាវកោ

ឥទ្ធិមន្តានំ សោ អគ្គោ  សទា សោត្ថឹ ករោតុ នោ ។

ព្រះមហាថេរៈអង្គនោះ មានព្រះនាមថា មោគ្គល្លាន ជាអគ្គសាវកទីពីរ កំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានឫទ្ធិ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[៨១] មហាកស្សបត្ថេរោបិ    ឧត្តត្តកនកន្និភោ

ធុតគុណាគ្គនិក្ខិត្តោ    តតិយោ សត្ថុសាវកោ ។

សូមព្រះមហាកស្សបត្ថេរ ជាអ្នកមានពណ៌សម្បុរដូចជាដុំមាស ទ្រទ្រង់នូវតំណែងកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកទ្រទ្រង់ធុតង្គ ជាសាវកអង្គទីបីរបស់ព្រះសាស្តា ។

[៨២] អរញ្ញវាសាភិរតោ    បំសុកូលធរោ មុនិ
សុគតសាសនធរោ    សទា សោត្ថឹ ករោតុ នោ ។

*ជាអ្នកត្រេកអរនៅក្នុងព្រៃ ទ្រទ្រង់សំពត់បង្សុកូល ជាព្រះមុនីដែលទ្រទ្រង់ពាក្យបង្រៀនរបស់ព្រះសុគត ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៨៣] អាបត្តិអនាបត្តិយា    សតេកិច្ឆាយ កោវិទោ
វិនយេ អគ្គនិក្ខិត្តោ    ឧបាលិ សត្ថុវណ្ណិតោ ។

*សូមព្រះឧបាលិត្ថេរ ជាអ្នកឈ្លាសក្នុងអាបត្តិនិងអនាបត្តិ ឈ្លាសក្នុងអាបត្តិដែលកែខៃបាន និងកែខៃមិនបាន ព្រះសាស្ដាទ្រង់សរសើរហើយ បានទទួលតំណែងថា ជាអ្នកកំពូលក្នុងព្រះវិន័យ ។*

[៨៤] វិនយេ បារមិប្បត្តោ    វិនយគ្គោចរោ មុនិ
ករោតុ នោ មហាសន្តឹ    សោត្ថ្យាភោគ្យំ ទទាតុ នោ។

*ជាអ្នកដល់នូវត្រើយក្នុងព្រះវិន័យ ជាព្រះមុនីមានព្រះវិន័យជាទីគោចរ (គឺនឹកដល់រឿងព្រះវិន័យស្មើ) ចូរប្រទាននូវសេចក្ដីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ ចូរប្រទាននូវសួស្ដីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៨៥] អនុរុទ្ធមហាថេរោ ទិព្វចក្ខុនមុត្តមោ
ញាតិសេដ្ឋោ ភគវតោ សោត្ថ្យារោគ្យំ ទទាតុ នោ ។

*សូមព្រះអនុរុទ្ធត្ថេរ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានទិព្វចក្ខុ ជាញាតិដ៏ប្រសើររបស់ព្រះដ៏មានព្រះភាគ ចូរប្រទាននូវសួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយសព្វៗកាល ។*

[៨៦] ឧច្ចាកុលិកានំ អគ្គោ ភទ្ទិយោ សុសមាហិតោ
កាឡិគោធាយ បុត្តោ ច សទា សោត្ថី ករោតុ នោ ។

*សូមព្រះភទ្ទិយត្ថេរ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានត្រកូលខ្ពង់ខ្ពស់ ជាអ្នកមានចិត្តមាំ ជាបុត្ររបស់នាងកាឡិគោធា ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយសព្វៗកាល ។*

[៨៧] អានន្ទោ ពុទ្ធុបដ្ឋាកោ សង្គីតិសាធុសម្មតោ
ពហុស្សុតោ ធម្មធរោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះអានន្ទត្ថេរ ជាពុទ្ធុបដ្ឋាក បានទទួលតំណែងកំពូលថា ជាអ្នកដំណើរការល្អក្នុងសង្គាយនា ជាពហុស្សូត ទ្រទ្រង់ធម៌ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៨៨] កិមិលោ សិរិសម្បន្នោ មហាសុខសមប្បិតោ
មហាវីណាសវោ ជាតោ មហាសន្តិ ករោតុ នោ ។

សូមព្រះកិមិលត្ថេរ ជាអ្នកបរិបូណ៌ដោយសិរី ប្រកបដោយ
មហាសុខ ជាព្រះមហាខីណាស្រព ចូរប្រទាននូវសេចក្ដី
ស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[៨៩] គុរាសំ វសត្វាន    បសន្នោ ពុទ្ធសាសនេ

ភគុ ចារហតំ បត្តោ    សទា សោត្ថឹ ករោតុ នោ ។

សូមព្រះភគុត្ថេរ ជាអ្នកជ្រះថ្លាក្នុងពាក្យបង្រៀនរបស់ព្រះពុទ្ធ
ជាម្ចាស់ បានទម្លុះជាព្រះអរហន្ត ចូរប្រទាននូវសួស្ដីដល់ខ្ញុំ
ទាំងឡាយ សព្វៗកាល ។

[៩០] កុលប្បសាទជនកោ    កាឡុទាយី មហិទ្ធិកោ

ឯតទគ្គដ្ឋិតោ ថេរោ    សទា សោត្ថឹ ករោតុ នោ ។

សូមព្រះកាឡុទាយិត្ថេរ ជាអ្នកមានឫទ្ធិច្រើន ញ៉ាំងសេចក្ដី
ជ្រះថ្លារបស់ត្រកូលឲ្យកើតឡើង ទ្រទ្រង់នៅក្នុងតំណែង
ឯតទគ្គៈ ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[៩១] សេដ្ឋោ ធម្មកថិកានំ    តិណ្ណំ វេទាន ចារគូ

បុណ្ណោ មន្តានិយាបុត្តោ ថេរោ សោត្ថឹ ករោតុ នោ។

សូមព្រះបុណ្ណត្ថេរ ជាបុត្ររបស់នាងមន្តានី ជាអ្នកកំពូល
លើសជាងភិក្ខុទាំងឡាយ អ្នកជាធម្មកថិក ជាអ្នកដល់
នូវត្រៃវេទ ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយសព្វៗកាល។

[៩២] ភារទ្វាជោ មហាថេរោ សីហនាទានមុត្តមោ
ឋបិតោ អគ្គឋានម្ហិ សទា សោត្ថី ករោតុ នោ ។

*សូមព្រះបិណ្ឌោលភារទ្វាជមហាថេរ ជាអ្នកទ្រទ្រង់តំណែង កំពូលលើសជាងភិក្ខុទាំងឡាយ អ្នកបន្លឺសីហនាទ ចូរ ប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[៩៣] សង្ខិត្តភាសិតមត្ថំ វិត្ថារេន វិជានកោ
កច្ចានោ ភវវិស្សេហោ ថេរោ សោត្ថី ករោតុ នោ ។

*សូមព្រះកច្ចាយនត្ថេរ ជាអ្នកយល់សេចក្តីដែលព្រះពុទ្ធជា ម្ចាស់ ត្រាស់ទុកដោយសង្ខេប ឲ្យពិស្តារបាន ជាអ្នក ប្រាសចាកសេចក្តីជំពាក់ក្នុងលោក ចូរប្រទាននូវសួស្តីដល់ ខ្ញុំទាំងឡាយ សព្វៗកាល។*

[៩៤] លកុណ្ឌកភទ្ទិយោ ថេរោ មញ្ជុស្សរានមុត្តមោ
ឋបិតោ អគ្គឋានម្ហិ សទា សោត្ថី ករោតុ នោ ។

*សូមព្រះលកុណ្ឌកភទ្ទិយត្ថេរ ជាអ្នកកំពូលលើសជាងភិក្ខុ ទាំងឡាយ អ្នកមានសំឡេងពីរោះ ចូរប្រទាននូវសួស្តីដល់ ខ្ញុំទាំងឡាយ សព្វៗកាល។*

[៩៥] អរណវិហារិនំ អគ្គោ ទក្ខិណេយ្យោ អនុត្តរោ
សុភូតិ ភូតទមនោ ថេរោ សោត្ថី ករោតុ នោ ។

សូមព្រះសុភូតិត្ថេរ ជាអ្នកកំពូលលើសជាងភិក្ខុទាំងឡាយ
អ្នកនៅដោយធម៌មិនមានកិលេស ជាអ្នកគួរទទួលនូវទក្ខិណា
ដ៏ប្រសើរ ជាអ្នកណែនាំវេនេយ្យជន ចូរប្រទាននូវសួស្តី
ដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[៩៦] អរញ្ញវាសិនំ អគ្គោ   រេវតោ ខទិរវនិយោ
វិវេកាភិរតោ ថេរោ   សទា សោត្ថឹ ករោតុ នោ ។

សូមព្រះរេវតត្ថេរ ជាអ្នកអាស្រ័យនៅក្នុងព្រៃ ជាអ្នកកំពូល
លើសជាងភិក្ខុទាំងឡាយ អ្នកនៅក្នុងព្រៃជាវត្ត ជាអ្នក
ត្រេកអរដ៏ក្រៃលែងក្នុងវិវេក ចូរប្រទាននូវសួស្តី
ដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[៩៧] ឈាយីនំ ឧត្តមោ ថេរោ   កង្ខារេវតនាមកោ
សមាធិឈានកុសលោ   សទា សោត្ថឹ ករោតុ នោ ។

សូមព្រះកង្ខារេវតត្ថេរ ជាអ្នកកំពូលលើសជាងភិក្ខុទាំង
ឡាយ អ្នកទម្លុះឈាន អ្នកជំនាញក្នុងសមាធិនិងឈាន
ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[៩៨] សោណោ ច កោឡិវិសោបិ អារទ្ធវីរិយានមុត្តមោ
បហិតត្តោ សទា ថេរោ   សោត្ថឹ ផាសុំ ករោតុ នោ ។

សូមព្រះសោណកោឡិវិសត្ថេរ ជាអ្នកមានចិត្តមាំ ជាអ្នក

*កំពូលលើសជាងភិក្ខុទាំងឡាយ អ្នកប្រារព្ធសេចក្ដីព្យាយាម ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[៩៩] កល្យាណវាក្ករណានំ សោណោ កុដិកណ្ណោបិ ច
អគ្គោតិ វណ្ណិតោ ថេរោ សោត្ថឹ ផាសុំ ករោតុ នោ ។

*សូមព្រះសោណកុដិកណ្ណត្ថេរ ជាអ្នកដែលព្រះសាស្ដាទ្រង់សរសើរថា ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកពោលវាចាពីរោះ ចូរប្រទាននូវផាសុកគឺសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០០] លាភីនមុត្តមោ ថេរោ សីវលិ ឥតិ វិស្សុតោ
សោ រតោ បច្ចយាទិម្ហិ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះថេរៈប្រាកដនាមថា សីវលី ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានលាភ តែប្រាថ្នាតិចក្នុងបច្ច័យជាដើម ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០១] សទ្ធាធិមុត្តានំ អគ្គោ វក្កលិ ឥតិ នាមកោ
ធាមោជ្ជពហុលោ ថេរោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះថេរៈព្រះនាមថា វក្កលិ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកបង្អោនទៅដោយសទ្ធា អ្នកច្រើនដោយប្រាមោទ្យ ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០២] រាហុលោ ពុទ្ធបុត្តោបិ    សិក្ខាកាមានមុត្តមោ

ទាយាទោ សព្វធម្មេសុ    មហាសន្តិ ករោតុ នោ ។

*សូមព្រះរាហុលត្ថេរ ជាព្រះពុទ្ធបុត្រ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកប្រាថ្នាសិក្សា ជាទាយាទក្នុងធម៌ទាំងពួង ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០៣] សទ្ធាយ បព្វជិត្វាន    រដ្ឋបាលោ បរក្កមី

ឯតទគ្គេ ឋិតោយេវ    សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះរដ្ឋបាលត្ថេរ អ្នកបួសហើយដោយសទ្ធា មានសេចក្តីព្យាយាម ទ្រទ្រង់ក្នុងតំណែងឯតទគ្គៈដោយពិត ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០៤] កុណ្ឌធានោ មហាថេរោ    សលាកំ បឋមំ គតោ

ឋបិតោយេវ ឋានម្ហិ    សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះកុណ្ឌធានមហាថេរ អ្នកបានទទួលនូវសលាកជាទីមួយ អ្នកទ្រទ្រង់នូវតំណែងឯតទគ្គៈ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០៥] បដិភាណវន្តានម្បិ    អគ្គោតិ ពុទ្ធវណ្ណិតោ

វង្គីសោ អរហា សេដ្ឋោ    សទា សោត្ថឹ ករោតុ នោ ។

សូមព្រះវង្គីសត្ថេរ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សរសើរថា ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានបដិភាណ ជាព្រះអរហន្តដ៏ប្រសើរ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[១០៦] សមន្តបាសាទិកានំ អគ្គដ្ឋានម្ហិ ឋបិតោ

ឧបសេនោ វង្គន្តបុត្តោ សទា សោត្ថី ករោតុ នោ ។

សូមព្រះឧបសេនវង្គន្តបុត្តត្ថេរ អ្នកទ្រទ្រង់ក្នុងតំណែងជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានបរិស័ទគួរជ្រះថ្លា ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[១០៧] ទព្វោ មល្លបុត្តោ ថេរោ សេនាសនាបញ្ញាបកោ

ឋបិតោ អគ្គដ្ឋានម្ហិ សទា សោត្ថី ករោតុ នោ ។

សូមព្រះទព្វត្ថេរ ជាមល្លបុត្រ អ្នកទ្រទ្រង់តំណែងឯតទគ្គៈ អ្នកចាត់ចែងសេនាសនៈ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[១០៨] បិលិន្ទវច្ឆសមណោ ទេវតានំ បិយោ អហុ

ឋបិតោ អគ្គដ្ឋានម្ហិ សោត្ថាភាគ្យំ ទទាតុ នោ ។

សូមព្រះបិលិន្ទវច្ឆត្ថេរ ដែលជាទីស្រឡាញ់របស់ពួកទេវតា អ្នកទ្រទ្រង់តំណែងឯតទគ្គៈ ចូរប្រទាននូវសួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[១០៩] ពាហិយោ ទារុចីរិយោ ខិប្បាភិញ្ញានមុត្តមោ

ករោតុ នោ មហាសន្តឹ អារោគ្យញ្ច ជយំ សទា ។

*សូមព្រះពាហិយទារុចីរិយត្ថេរ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកត្រាស់ដឹងរហ័ស ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែង សុខភាពល្អ និងជ័យជម្នះដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១១០] កុមារកស្សបត្ថេរោ ចិត្តកថីនមុត្តមោ

មិច្ឆាវិតក្កុបច្ឆេទោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះកុមារកស្សបត្ថេរ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានវាចាដ៏វិចិត្រ កម្ចាត់មិច្ឆាវិតក្កៈបាន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១១១] បដិសម្ភិទាបត្តានំ អគ្គដ្ឋានម្ហិ ឋបិតោ

កោដ្ឋិតោ អរហា សេដ្ឋោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះកោដ្ឋិតត្ថេរ ជាអ្នកទ្រទ្រង់តំណែង កំពូលលើសជាងភិក្ខុទាំងឡាយ អ្នកទម្ទ៉ះបដិសម្ភិទា ជាព្រះអរហន្តដ៏ប្រសើរ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១១២] អប្បាពាធោ មហាថេរោ អប្បាពាធានមុត្តមោ

ពាក្កុលោ អរហា ជាតោ សទា សោត្ថឹ ករោតុ នោ ។

សូមព្រះពាកុលមហាថេរ អ្នកមានអាពាធតិច ជាកំពូល
លើសជាងភិក្ខុទាំងឡាយ អ្នកមានអាពាធតិច ជាព្រះអរហន្ត
ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[១១៣] បុព្វេនិវាសវេទីនំ អគ្គោតិ ពុទ្ធវណ្ណិតោ
សោភិតោ នាម សោ ថេរោ សទា សោត្ថឹ ករោតុ នោ។

សូមព្រះសោភិតត្ថេរ ដែលព្រះពុទ្ធទ្រង់ត្រាស់សរសើរថា
ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នករលឹកជាតិបាន
ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[១១៤] មហាកប្បិនត្ថេរោបិ ភិក្ខុ ឱវាទកោ អហុ
កុសលោ ឱវាទទានេ សទា សោត្ថឹ ករោតុ នោ ។

សូម្បីព្រះមហាកប្បិនត្ថេរ ជាអ្នកឲ្យឱវាទដល់ភិក្ខុ ជាកំពូល
លើសក្នុងការបង្រៀន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ
សព្វៗកាល ។

[១១៥] ភិក្ខុនោវាទកានគ្គោ នន្ទកោ ឥតិ វិស្សុតោ
ចាលេតុ នោ សទា ថេរោ សោត្ថឹ ជាសុំ ករោតុ នោ ។

សូមព្រះថេរៈប្រាកដនាមថា នន្ទកៈ ជាកំពូលលើសជាង
ភិក្ខុទាំងឡាយ អ្នកឲ្យឱវាទដល់នាងភិក្ខុនី ចូរគ្រប់គ្រងនូវ
ខ្ញុំទាំងឡាយ សព្វៗកាល ចូរប្រទាននូវផាសុកភីសួស្តី
ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[១១៦] ឥន្ទ្រិយេសុ គុត្តទ្វារោ  អគ្គដ្ឋានេ ឋិតោ អហុ
នន្ទត្ថេរោ វសិប្បត្តោ  សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះនន្ទត្ថេរ ជាអ្នកគ្រប់គ្រងនូវទ្វារក្នុងឥន្ទ្រិយហើយ ទ្រទ្រង់ក្នុងតំណែងឯតទគ្គៈ ដល់ភាពជំនាញហើយ (ក្នុងសមាបត្តិ) ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយសព្វៗកាល។*

[១១៧] តេជោធាតុកុសលានំ  អគ្គដ្ឋានម្ហិ ឋបិតោ
សាគតោ នាម សោ ថេរោ សោត្ថឹ ផាសុំ ករោតុ នោ។

*សូមព្រះថេរៈព្រះនាម សាគតៈ អ្នកទ្រទ្រង់តំណែងកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកឈ្លាសក្នុងតេជោកសិណ ចូរប្រទាននូវផាសុកគឺសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១១៨] សញ្ញាវិវដ្តកុសលោ  បធានោ ភាវនារតោ
ពុទ្ធសិស្សោ មហាបន្ថោ  មហាសន្តឹ ករោតុ នោ ។

*សូមព្រះមហាបន្ថកត្ថេរ អ្នកឈ្លាសក្នុងវិបស្សនាដែលចេញចាកសញ្ញា (មាននិច្ចសញ្ញាជាដើម) មានសេចក្តីព្យាយាមត្រេកអរក្នុងការអប់រំចិត្ត ជាសិស្សរបស់ព្រះសាស្តា ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១១៩] ចូឡបន្ថកត្ថេរោបិ    មនោមយាភិនិម្មិតោ

ឋបិតោ អគ្គដ្ឋានម្ហិ    សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះចូឡបន្ថកត្ថេរ អ្នកនិម្មិតកាយដែលសម្រេចដោយ (ឈាន) ចិត្ត អ្នកទ្រទ្រង់នូវតំណែងឯតទគ្គៈ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១២០] បដិភាណេយ្យកានំ តុ    អគ្គដ្ឋានម្ហិ ឋបិតោ

រាធោ ថេរោ មហាសោត្ថឹ ករោតុ នោ អនាមយំ ។

*សូមព្រះរាធត្ថេរ អ្នកទ្រទ្រង់នូវតំណែង កំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានបដិភាណ ចូរប្រទាននូវសួស្តីដ៏ធំក្រៃលែងនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១២១] លូខចីវរធរានំ    ភិក្ខូនំ ឧត្តមោ អហុ

មោឃរាជមហាថេរោ    មហាសន្តឹ ករោតុ នោ ។

*សូមព្រះមោឃរាជមហាថេរ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកទ្រទ្រង់ចីវរសៅហ្មង ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១២២] វិមលោ វិមលប្បញ្ញោ    សូរធោ សុសមាហិតោ

រជោ ន លិម្បតិ ខន្ធេ    មហាសន្តឹ ករោតុ នោ ។

សូមព្រះវិមលត្ថេរ អ្នកមានបញ្ញា ប្រាសចាកមន្ទិល មាន
រូបស្អាត មានចិត្តតាំងមាំល្អ ធុលីគឺកិលេស មិនមានជាប់
ក្នុងខន្ធ ៥ របស់លោក ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំ
ក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[១២៣] ធម្មបាលោ មហាបាលោ មហាធម្មធរោ យតិ

មហាខីណាសវោ លោកេ មហាសន្តឹ ករោតុ នោ ។

សូមព្រះមហាបាលត្ថេរ អ្នករក្សាធម៌ដ៏ប្រសើរ ទ្រទ្រង់ធម៌
ដ៏ប្រសើរ ជាព្រះមហាខីណាស្រព ចូរប្រទាននូវសេចក្តី
ស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[១២៤] ចក្ខុបាលោ មហាថេរោ បធានោ សីលសំវុតោ

បហិតត្តោ មហាកាយោ មហាសន្តឹ ករោតុ នោ ។

សូមព្រះចក្ខុបាលមហាថេរ អ្នកមានសេចក្តីព្យាយាម
សង្រួមក្នុងសីល អ្នកមានចិត្តតាំងមាំ មានពួកធម៌ដ៏ប្រសើរ
ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ
សព្វៗកាល ។

[១២៥] សព្វវេរភយាតីតោ នារទោ អាសវក្ខយោ

មហាសន្តិករោ លោកេ សទា សោត្ថឹ ករោតុ នោ ។

សូមព្រះនារទត្ថេរ អ្នកកន្លងផុតចាកពៀរនិងភ័យទាំងពួង

*អស់អាសវៈហើយ អ្នកសាងសេចក្ដីស្ងប់ដ៏ធំក្រៃលែង ក្នុងលោក ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១២៦] ពុទ្ធបូជាយ និរតោ ជិនភត្តិបរាយនោ
សទ្ធម្មសវនោ ថេរោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះសទ្ធម្មសវនត្ថេរ អ្នកត្រេកអរក្នុងការបូជានូវព្រះពុទ្ធជាម្ចាស់ មានភក្ដីក្នុងព្រះជិនស្រី ជាទីតាំង ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១២៧] បច្ចិមភវសម្បត្តោ គោតមោ ភាវនារតោ
ភគក្ខយមនុប្បត្តោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះគោតមត្ថេរ ជាអ្នកដល់ទីបំផុតនៃភពហើយ ត្រេកអរក្នុងសេចក្ដីព្យាយាម បានដល់នូវកិរិយាអស់ទៅនៃភគៈ ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១២៨] សេនាសនេសុ សប្បាយំ លទ្ធា ឈានំ សមារភិ
គោធិកោ ពុទ្ធឈាយន្តោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះគោធិកត្ថេរ បានទទួលនូវសេនាសនៈ ជាទីសប្បាយហើយ ប្រារព្ធឈាន សំឡឹងមើលព្រះពុទ្ធជាម្ចាស់ ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១២៩] ពុទ្ធេ បសន្នមានសោ  សុពាហុ បញ្ជលីកតោ
ខីណាសវោ វសីភូតោ  មហាសន្តឹ ករោតុ នោ ។

*សូមព្រះសុពាហុត្ថេរ ជាអ្នកមានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់ បានធ្វើអញ្ជលី (កាល ៩៤ កប្បកន្លងមកហើយ) ជាព្រះខីណាស្រព មានជំនាញ (ក្នុងសមាបត្តិ) ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៣០] វិបស្សនាយ បសុតោ  វល្លិយោ សុសមាហិតោ
សតោ ឈាយី វនេវាសី  សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះវល្លិយត្ថេរ ជាអ្នកខ្វល់ខ្វាយក្នុងវិបស្សនាភាវនា មានចិត្តតាំងមាំល្អហើយ មានសតិ សំឡឹងឈាន នៅក្នុងព្រៃជានិច្ច ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣១] ឧត្តិយោ វិនយធរោ  អតិក្កន្តោ នរាមរេ
ធារេន្តោ អន្តិមំ ទេហំ  សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះឧត្តិយត្ថេរ អ្នកទ្រទ្រង់ព្រះវិន័យ កន្លងផុតមនុស្សនិងទេវតា អ្នកទ្រទ្រង់កាយដែលមានក្នុងភពជាទីបំផុត ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣២] វិមលោ វិរជោជល្លោ  ជាតោ បណ្ឌរកេតុនា
ពិម្ពិសារទ្ធជោ ថេរោ  សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះវិមលកោណ្ឌញ្ញត្ថេរ ជាអ្នកប្រាសចាកនូវធុលីគឺកិលេស បង្កើតជាព្រះភិក្ខុនិងព្រះមុនី ជាអ្នកមានបញ្ញាបរិសុទ្ធ ដូចជាទង់ព្រះបាទពិម្ពិសារ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣៣] រម្មារញ្ញេ វសិត្វាន   ភាវេន្តោ កុសលំ ពហុំ
យោគក្ខេមមនុប្បត្តោ   សភិយោ សន្តឹ ករោតុ នោ ។

*សូមព្រះសភិយត្ថេរ ជាអ្នកនៅក្នុងព្រៃដែលគួររីករាយ ចម្រើនកុសលជាអនេក ទម្លុះព្រះនិព្វាន ជាទីក្សេមចាកកិលេស ចូរប្រទាននូវសេចក្តីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣៤] បុព្វេនិវាសំ ជានន្តោ   ទិព្វចក្ខុវិសោធនោ
នាគិរហាតំ បត្តោ   សោត្ថ្យារោគ្យំ ទទាតុ នោ ។

*សូមព្រះនាគិតត្ថេរ ជាអ្នករលឹកជាតិក្នុងកាលមុនបាន ជាអ្នកជម្រះនូវទិព្វចក្ខុឲ្យបរិសុទ្ធ បានដល់នូវភាពជាព្រះអរហន្តហើយ ចូរប្រទាននូវសួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣៥] ចាតិមោក្ខមនុប្បត្តោ   វិជយោ រញ្ញគោចរោ
លាភាលាភី តថាសំសី   សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះវិជយត្ថេរ ជាអ្នកដល់ព្រមដោយបាតិមោក្ខ-សំវរសីល ជាអ្នកមានព្រៃជាទីគោចរ មានលាភទាំងតូចទាំងធំ បានពោលសរសើរតាមសភាពពិត ចូរប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣៦] តណ្ហាជដំ វិជដេត្វា វឌ្ឍេត្វាន វិបស្សនំ

សង្ឃរក្ខិតោ មហាថេរោ មហាសន្តឹ ករោតុ នោ ។

*សូមព្រះសង្ឃរក្ខិតមហាថេរ ជាអ្នកកាប់ក្ការនូវជដៈគឺតណ្ហា ចម្រើនវិបស្សនាហើយ ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៣៧] អរញ្ញវាសាភិរតោ ភវនេត្តិសមូហតោ

ធម្មានំ ធារមិប្បត្តោ ឧត្តរោ ធាតុ នោ ភយា ។

*សូមព្រះឧត្តរត្ថេរ ជាអ្នកត្រេកអរក្នុងការនៅព្រៃ ជាអ្នកដកនូវតណ្ហា ដែលនាំទៅកាន់ភពបាន ជាអ្នកដល់នូវត្រើយនៃធម៌ទាំងឡាយ ចូរគ្រប់គ្រងរក្សានូវខ្ញុំទាំងឡាយ ឲ្យផុតចាកភ័យវិបត្តិ ។*

[១៣៨] បុព្វេ បុញ្ញានិ កត្វាន បុព្វយោគំ សមារភិ

ឧសភោរហាតំ បត្តោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះឧសភត្ថេរ ជាអ្នកធ្វើបុណ្យក្នុងកាលមុនហើយ*

ប្រារព្ធកម្មដ្ឋាន ដែលជាចំណែកខាងដើម (នៃមគ្គ) បាន
ទម្លុះភាពជាព្រះអរហន្ត ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ
សព្វៗកាល។

[១៣៩] សមាបត្តិសមាបន្នោ ឆឡភិញ្ញោ មហិទ្ធិកោ
សិវកោ ពុទ្ធឈាយន្តោ សទា សោត្ថិំ ករោតុ នោ ។

សូមព្រះសិវកត្ថេរ ជាអ្នកដល់ព្រមដោយសមាបត្តិ មាន
អភិញ្ញា ៦ មានឫទ្ធិច្រើន ជាអ្នកសំឡឹងមើលព្រះពុទ្ធជា
ម្ចាស់ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៤០] សត្តារិយធនោ ថេរោ ធនិយោ ធម្មសាគរោ
វដ្តសំសារគមនោ សទា សោត្ថិំ ករោតុ នោ ។

សូមព្រះធនិយត្ថេរ ជាអ្នកមានអរិយទ្រព្យ ៧ ប្រការ ជា
សាគរនៃធម៌ លះការប្រព្រឹត្តទៅក្នុងសង្សារវដ្តហើយ ចូរ
ប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៤១] បញ្ចក្ខន្ធេ បរិញ្ញាយ ភាវយិត្វាន និព្វុតឹ
បត្វាន បរមំ សន្តឹ បោសិយោ បាតុ នោ ភយា។

សូមព្រះបោសិយត្ថេរ ជាអ្នកកំណត់ដឹងនូវបញ្ចក្ខន្ធហើយ
ចម្រើននូវការរំលត់កិលេស បានដល់នូវសេចក្តីស្ងប់
ដ៏ក្រៃលែង ចូរគ្រប់គ្រងរក្សានូវខ្ញុំទាំងឡាយ ឲ្យផុត
ចាកភ័យវិបត្តិ ។

[១៤២] ឧបនិស្សយសម្បន្នោ ឧជ្ជយោ ពុទ្ធមាមកោ
លោកត្ថុបសុតោ ថេរោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះឧជ្ជយត្ថេរ ជាអ្នកសម្បូរដោយធម៌ដែលជាហេតុចេញចាកវដ្ដៈ ជាអ្នកគោរពក្នុងព្រះពុទ្ធ ជាអ្នកខ្វល់ខ្វាយដើម្បីប្រយោជន៍ដល់សត្វលោក ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៤៣] ពុទ្ធប្បសាទសម្បន្នោ បព្វជិ ជិនសាសនេ
សញ្ជយោ នាម សោ ថេរោ សទា សោត្ថី ករោតុ នោ។

*សូមព្រះថេរៈព្រះនាមថា សញ្ជយៈ ជាអ្នកដល់ព្រមដោយសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់ បួសហើយក្នុងសាសនារបស់ព្រះជិនស្រី ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៤៤] មារញ្ជយោ មហាថេរោ រាមណេយ្យោ មហិទ្ធិកោ
និព្វាននិន្នចិត្តោ សោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះមហាថេរៈនាមថា រាមណេយ្យៈ ជាអ្នកមានឫទ្ធិច្រើន មានចិត្តបង្អោនទៅព្រះនិព្វាន ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៤៥] ឧភោ ធាបញ្ញ បុញ្ញញ្ញ វីតិវត្តោ អនាសវោ

វីរត្តេរោ រហោប្យត្តោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះវីរត្ថេរ ជាអ្នកឆ្លងផុតចាកបាប និងបុណ្យទាំងពីរ ប្រការ អស់អាសវៈហើយ ដល់ភាពជាព្រះអរហន្ត ចូរ ប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៤៦] បុណ្ណមាសមហាថេរោ បំសុកូលធរោ យតិ

បុព្វកិច្ចវិធី កត្វា មហាសន្តឹ ករោតុ នោ ។

*សូមព្រះបុណ្ណមាសមហាថេរ ជាអ្នកទ្រទ្រង់សំពត់បង្សុកូល ធ្វើនូវវិធីដែលជាបុព្វកិច្ចខាងដើមហើយ ចូរប្រទាននូវសេចក្ដីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៤៧] បញ្ចឆិន្នោ បញ្ចជហោ បញ្ច ចុត្តរិភាវនោ

បញ្ចសង្គាតិគោ ថេរោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះបញ្ចសង្គាតិគត្ថេរ ជាអ្នកកាត់សំយោជនៈខាងក្រោម ៥ ជាអ្នកលះសំយោជនៈខាងលើ ៥ ជាអ្នកអប់រំឥន្ទ្រិយ ៥ ឲ្យក្រៃលែងៗទៅ ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៤៨] បុព្វយោគំ វិចារេន្តោ ជិនភត្តិបរាយនោ

ពេលដ្ឋសីសោ វំសធរោ សទា សោត្ថឹ ករោតុ នោ ។

សូមព្រះពេលដ្ឋសីសត្ថេរ ជាអ្នកពិចារណាសេចក្តីខ្វល់ខ្វាយក្នុងជាតិមុន មានភក្តីក្នុងព្រះជិនស្រីជាទីតាំង ជាអ្នកទ្រទ្រង់វង្សត្រកូល ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៤៩] បញ្ចុប្បន្នេហិ អភយោ និកន្តិ នត្ថិ ជីវិតេ

អជិតោ សោ មហាថេរោ មហាសន្តឹ ករោតុ នោ ។

សូមព្រះមហាថេរៈនាម អជិតៈ ជាអ្នករួចភ័យចាកខន្ធ ៥ ដែលកើតឡើងហើយ មិនមានសេចក្តីត្រេកអរក្នុងជីវិត ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៥០] វិវដ្ដនិស្សយេ បុញ្ញោ កត្វា សម្ពុទ្ធភត្តិមា

កុល្លត្ថេរោរហប្បត្តោ មហាសន្តឹ ករោតុ នោ ។

សូមព្រះកុល្លត្ថេរ ជាអ្នកមានភក្តីក្នុងព្រះសម្មាសម្ពុទ្ធជាម្ចាស់ បំពេញបុណ្យអាស្រ័យព្រះនិព្វាន បានដល់នូវភាពជាព្រះអរហន្តហើយ ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៥១] វិបស្សី ធម្មទាយាទោ ថេរោ និគ្រោធនាមកោ

និព្វានគមនសន្និដ្ឋោ សទា សោត្ថឹ ករោតុ នោ ។

សូមព្រះថេរៈនាមថា និគ្រោធៈ ជាអ្នកសំឡឹងត្រៃលក្ខណ៍ (ដោយវិបស្សនាបញ្ញា) ជាធម្មទាយាទ ឃើញច្បាស់នូវធម៌ដែលធ្វើឲ្យដល់នូវព្រះនិព្វាន ចូរប្រទាននូវសេចក្តីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៥២] តិស្សោ វិជ្ជា អនុប្បត្តោ សុគន្ធោ នាម សោ រហា
សព្វទាបបរិក្ខីណោ សទា សោត្ថឹ ករោតុ នោ ។

សូមព្រះអរហន្តនាមថា សុគន្ធៈ ជាអ្នកបានដល់នូវវិជ្ជា ៣ មានបាបទាំងពួងអស់រលីងហើយ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៥៣] នន្ទិយោ សទ្ធាសម្បន្នោ ជិតក្លេសោ មហាថេរោ
អភិញ្ញាចារមិប្បត្តោ សទា សោត្ថឹ ករោតុ នោ ។

សូមព្រះនន្ទិយមហាថេរ ជាអ្នកដល់ព្រមដោយសទ្ធា ឈ្នះកិលេសហើយ ជាអ្នកដល់នូវត្រើយនៃអភិញ្ញា ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៥៤] កិលេសា ឈាបិតា យេន ជិតជម្មារតេន សោ
កម្មារបុត្តវិមលោ សទា សោត្ថឹ ករោតុ នោ ។

ព្រះថេរៈអង្គណា ជាអ្នកត្រេកអរក្នុងធម៌ដែលជាគ្រឿងវិជិតមារ ដុតកិលេសបានហើយ ព្រះថេរៈមាននាមថា វិមលៈ

*ជាបុត្ររបស់ជាងមាស ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ*
*សព្វៗកាល។*

[១៥៥] ទេវលោកមនុស្សេសុ    អនុកុត្វា វិភូតិយោ
តិស្សត្ថេរោ មហាភូតោ    មហាសន្តឹ ករោតុ ណោ ។

*សូមព្រះតិស្សត្ថេរ ជាអ្នកសោយសម្បត្តិក្នុងទេវលោក និង*
*មនុស្សលោកហើយ ជាព្រះអរហន្តដ៏ប្រសើរ ចូរប្រទាននូវ*
*នូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៥៦] សុវិមុត្តោ មហាណាគោ    តីហិ វដ្ដេហិ មុត្តកោ
សុមង្គលោ មហាថេរោ    មហាសន្តឹ ករោតុ ណោ ។

*សូមព្រះសុមង្គលមហាថេរ ជាអ្នករូបផុតល្អហើយ ជាព្រះ*
*អរហន្តដ៏ធំ ផុតហើយចាកកោងទាំង ៣ (គឺកោងផ្លូវកាយ*
*វាចា ចិត្ត)  ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែដល់ខ្ញុំ*
*ទាំងឡាយ សព្វៗកាល។*

[១៥៧] និរគ្គឡោ និរាសាសោ    មលខីលវិសោធនោ
វិវេកាភិរតោ គុត្តោ    សទា សោត្ថឹ ករោតុ ណោ ។

*សូមព្រះមហាថេរៈនាមថា គុត្តៈ ជាអ្នកមិនមានអវិជ្ជា*
*ប្រាសចាកតណ្ហា ជម្រះមន្ទិលឲ្យបរិសុទ្ធ ត្រេកអរក្រៃលែង*
*ក្នុងវិវេក អ្នកសង្រួមខ្លួនហើយ ចូរប្រទាននូវសួស្តីដល់ខ្ញុំ*
*ទាំងឡាយ សព្វៗកាល។*

[១៥៨] បវិវេកមនុប្បត្តោ គិរិមានន្ទនាមកោ
ភាវេន្តោ កុសលេ ធម្មេ សទា សោត្ថី ករោតុ នោ ។

*សូមព្រះថេរៈនាមថា គិរិមានន្ទ ជាអ្នកចម្រើននូវកុសលធម៌ បានដល់ហើយនូវវិវេក ៣ (គឺកាយវិវេក ចិត្តវិវេក និង ឧបធិវិវេក) ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៥៩] ពុទ្ធសាសនមារទ្ធោ សមិទ្ធិ ភាវនារតោ
សមិទ្ធិគុណសម្បន្នោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះសមិទ្ធិត្ថេរ ជាអ្នកព្យាយាមបដិបត្តិតាមពាក្យបង្រៀន របស់ព្រះពុទ្ធជាម្ចាស់ ជាអ្នកត្រេកអរក្នុងភាវនា ដល់ព្រម ដោយគុណនៃសេចក្តីសម្រេច ចូរប្រទាននូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល។*

[១៦០] អារាធិតជិនោ សន្តោ ជោតិត្ថេរោ មហារហា
វិមុត្តោ សព្វសំសារា សទា សោត្ថី ករោតុ នោ ។

*សូមព្រះជោតិត្ថេរ ជាអ្នកញ៉ាំងព្រះជិនស្រីឲ្យមានព្រះទ័យរីករាយហើយ ជាអ្នកស្ងប់ ជាព្រះអរហន្តដ៏ធំក្រៃលែង រួចផុតហើយចាកសង្សារវដ្តទាំងពួង ចូរប្រទាននូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល។*

[១៦១] សេនាសនានិ បន្តានិ   សេវន្តោ ឈានមារតិ

ឆឡភិញ្ញោ មហាចុន្ទោ   សទា សោត្ថី ករោតុ នោ ។

*សូមព្រះមហាចុន្ទត្ថេរ ជាអ្នកអាស្រ័យក្នុងសេនាសនៈដ៏ស្ងាត់ ចូលឈានហើយ ទ្រទ្រង់អភិញ្ញា ៦ ចូរប្រទាននូវសួស្តី ដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦២] ឆន្នត្ថេរោ សហជាតោ   សុណន្តោ ជិនសាសនំ

យោគក្ខេមមនុប្បត្តោ   សទា សោត្ថី ករោតុ នោ ។

*សូមព្រះឆន្នត្ថេរ ជាសហជាតនឹងព្រះពុទ្ធជាម្ចាស់ កាលជឿស្តាប់ពាក្យបង្រៀនរបស់ព្រះជិនស្រីហើយ បានដល់ហើយ នូវព្រះនិព្វាន ដែលជាទីក្សេមចាកកិលេស ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦៣] មេឃិយោ ពុទ្ធុបដ្ឋាកោ   ជិនភត្តិបរាយនោ

មិច្ឆាវិតក្កុបច្ឆេទោ   សទា សោត្ថី ករោតុ នោ ។

*សូមព្រះមេឃិយត្ថេរ ជាពុទ្ធុបដ្ឋាក មានភក្តីក្នុងព្រះជិនស្រី ជាទីតាំង កាត់មិច្ឆាវិតក្កៈហើយ ចូរប្រទាននូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល។*

[១៦៤] ឧបវាណោ មហាថេរោ   មហាកាយោ មហារហា

មហិទ្ធិកោ មហាតេជោ   សទា សោត្ថី ករោតុ នោ ។

*សូមព្រះឧបវាណមហាថេរ ជាអ្នកមានរាងកាយខ្ពស់ធំ ជាព្រះអរហន្តដ៏ធំក្រៃលែង មានឫទ្ធិដ៏ច្រើន មានអានុភាពច្រើន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦៥] សង្កិច្ចោ ចោរទមនោ    សព្វសំយោជនក្ខយោ
ចាលេតុ នោ សព្វភយា    សោត្ថាភាគ្យំ ទទាតុ នោ ។

*សូមព្រះសង្កិច្ចត្ថេរ ជាអ្នកទូន្មាននូវចោរ អស់សំយោជនៈទាំងពួង ចូរគ្រប់គ្រងនូវខ្ញុំទាំងឡាយឲ្យផុតចាកភ័យទាំងពួង ចូរប្រទាននូវសួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦៦] បញ្ហាព្យាករណោ ឆេកោ    មេត្តាឈានរតោ យតិ
សោចាកោ ចាយសម្បន្នោ    សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះសោបាកត្ថេរ ជាអ្នកឈ្លាសក្នុងការតបបញ្ហារបស់ព្រះពុទ្ធជាម្ចាស់ ត្រេកអរក្នុងឈាន ដែលប្រកបដោយមេត្តា បរិបូណ៌ដោយហេតុ (ក្នុងការទម្លុះមគ្គផល) ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦៧] ខេត្តសម្បត្តិសម្បត្តោ    វឌ្ឍមានោវ សោត្ថិនា
សុមនោ អរហា ជាតោ    សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះសុមនត្ថេរ ជាអ្នកដល់ព្រមដោយកាលដ៏សមគួរ*

(ក្នុងការទម្រមះធម៌) ជាអ្នកចម្រើនដោយសេចក្ដីសុខដ៏ពិត ជាព្រះអរហន្តហើយ ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៦៨] បិយោ ទេវមនុស្សានំ សានុត្ថេរោ ពហុស្សុតោ

មេត្តាឈាយី តមោឃាតីសទា សោត្ថឹ ករោតុ នោ ។

សូមព្រះសានុត្ថេរ ជាទីស្រឡាញ់នៃមនុស្សនិងទេវតាទាំងឡាយ ជាពហុស្សូត មានឈានប្រកបដោយមេត្តា ជាអ្នកទម្លាយនូវងងឹត គឺមោហៈ ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៦៩] យោ ច បុព្វេ កតំ ចាបំ កុសលេន បិធីយតិ

អង្គុលិមាលោ សោ ថេរោ សទា សោត្ថឹ ករោតុ នោ ។

ព្រះថេរៈអង្គណា បិទបាំងនូវបាបដែលខ្លួនធ្វើទុកក្នុងកាលមុនដោយកុសល ព្រះថេរៈមាននាមថា អង្គុលិមាល ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៧០] វិបស្សនាធុរា យេបិ ថេរា សមថយានិកា

ខីណាសវា មហាតេជា មហាតមវិនោទនា ។

សូម្បីព្រះថេរៈអង្គណា ជាវិបស្សនាយានិក ឬសមថយានិក ជាអ្នកអស់អាសវៈហើយ មានតេជៈច្រើន ជាអ្នកកម្ចាត់នូវងងឹតដ៏ធំ គឺមោហៈ ។

[១៧១] ឈានិកាឈានិកា យេចិ ធម្មាភិសមយានុយោ

សព្វេ សោត្ថឹ សទា ទេន្តុ ជយមារោគ្យមាយុនោ ។

*និងព្រះថេរៈទាំងឡាយអង្គឯណា បានទម្លុះធម៌ជាដើម ទាំងបានឈាន និងមិនបានឈាន សូមព្រះថេរៈទាំងឡាយអង្គនោះ ចូរប្រទាននូវសួស្តី ជ័យជម្នះ សុខភាពល្អ និងអាយុដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

## ព្រះមហាថេរី ១៣ អង្គ

[១៧២] រត្តញ្ញូនំ ភិក្ខុនីនំ		គោតមី ជិនមាតុច្ឆា

ថបិតា អគ្គឋានម្ហិ		សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះគោតមីថេរី ជាព្រះមាតុច្ឆារបស់ព្រះពុទ្ធជាម្ចាស់ ទ្រទ្រង់តំណែងកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកមានរាត្រីយូរ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៣] មហាបញ្ញានមគ្គជ្ជា		ខេមាថេរីតិ ចាកដា

សាវិកា ពុទ្ធសេដ្ឋស្ស		សទា សោត្ថឹ ករោតុ នោ ។

*សូមសាវិការបស់ព្រះពុទ្ធជាម្ចាស់ដ៏ប្រសើរ ប្រាកដនាមថាព្រះខេមាថេរី ទ្រទ្រង់តំណែងកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកមានបញ្ញាច្រើន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៤] ថេរី ឧប្បលវណ្ណា ច   ឥទ្ធិមន្តីនមុត្តមា

សាវិកា ពុទ្ធសេដ្ឋស្ស   សទា សោត្ថី ករោតុ នោ ។

*សូមព្រះឧប្បលវណ្ណាថេរី សាវិការបស់ព្រះពុទ្ធជាម្ចាស់ ដ៏ប្រសើរ ទ្រទ្រង់តំណែងកំពូលលើសជាងភិក្ខុនីទាំង ឡាយ អ្នកមានឫទ្ធិច្រើន ចូរប្រទាននូវសួស្តីដល់ ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៥] វិនយធរីនំ អគ្គា   បដាចារាតិ វិស្សុតា

ឋបិតា អគ្គដ្ឋានម្ហិ   សទា សោត្ថី ករោតុ នោ ។

*សូមព្រះថេរីប្រាកដនាមថា បដាចារា ទ្រទ្រង់តំណែងកំពូល លើសជាងភិក្ខុនីទាំងឡាយ អ្នកទ្រទ្រង់ព្រះវិន័យ ចូរប្រទាន នូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៦] ធម្មកថិកបវរា   ធម្មទិន្នាតិ នាមិកា

ឋបិតា អគ្គដ្ឋានម្ហិ   សទា សោត្ថី ករោតុ នោ ។

*សូមព្រះថេរីមាននាមថា ធម្មទិន្នា ទ្រទ្រង់តំណែងកំពូល លើសជាងភិក្ខុនីទាំងឡាយ អ្នកជាធម្មកថិកា ចូរប្រទាន នូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៧] ឈាយិកានំ ភិក្ខុនីនំ   នន្ទាថេរីតិ នាមេសា

អគ្គឋានេ ឋបិតា អហុ   សទា សោត្ថី ករោតុ នោ ។

សូមសាវិកានាមថា នន្ទាថេរី ទ្រទ្រង់តំណែងកំពូលលើស
ជាងភិក្ខុនីទាំងឡាយ អ្នកមានឈាន ចូរប្រទាននូវសួស្តី
ដល់ខ្ញុំទាំងឡាយ សព្វៗកាលៗ

[១៧៨] អារទ្ធវីរិយានំ អគ្គា សោណាថេរីតិ នាមិកា
ឋបិតា តត្ថ ឋានម្ហិ សទា សោត្ថី ករោតុ នោ ។

សូមព្រះថេរីនាមថា សោណា ទ្រទ្រង់តំណែងកំពូលលើស
ជាងភិក្ខុនីទាំងឡាយ អ្នកប្រារព្ធសេចក្តីព្យាយាម ចូរប្រទាន
នូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាលៗ

[១៧៩] ទិព្វចក្ខុកានំ អគ្គា ពកុលា ឥតិ វិស្សុតា
វិសុទ្ធនយនា សាបិ សទា សោត្ថី ករោតុ នោ ។

សូមព្រះថេរីប្រាកដនាមថា ពកុលា អ្នកមានចក្ខុដ៏ប្រសើរ
ជាកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកមានទិព្វចក្ខុ
ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាលៗ

[១៨០] កុណ្ឌលកេសា ភិក្ខុនី ខិប្បាភិញ្ញានមុត្តមា
ឋបិតាយេវ ឋានម្ហិ សទា សោត្ថី ករោតុ នោ ។

សូមភិក្ខុនីឈ្មោះថា កុណ្ឌលកេសា អ្នកទ្រទ្រង់តំណែងកំពូល
លើសជាងភិក្ខុនីទាំងឡាយ អ្នកត្រាស់ដឹងរហ័ស ចូរប្រទាន
នូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាលៗ

[១៨១] ថេរី ភទ្ទកាបិលានី    បុព្វជាតិមនុស្សរិ

តាសំយេវ ភិក្ខុនីនំ    អគ្គា សោត្ថិ ករោតុ នោ ។

*សូមព្រះភទ្ទាកាបិលានីថេរី អ្នករលឹកជាតិមុនបាន ជាកំពូល លើសជាងភិក្ខុនីទាំងឡាយ អ្នករលឹកជាតិបាន ចូរប្រទាន នូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៨២] ថេរី ច ភទ្ទកច្ចានា    មហាភិញ្ញានមុត្តមា

ជិនេន សុខទុក្ខំ សា    សទា សោត្ថិ ករោតុ នោ ។

*សូមព្រះភទ្ទាកច្ចានាថេរី (គឺព្រះនាងយសោធរា) អ្នករួមទុក្ខ រួមសុខរបស់ព្រះជិនស្រី ជាកំពូលលើសជាងភិក្ខុនីទាំង ឡាយ អ្នកមានអភិញ្ញាធំ ចូរប្រទាននូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល។*

[១៨៣] លូខចីវរធារីនំ    អគ្គា កិសាបិ គោតមី

ឋបិតា អគ្គឋានម្ហិ    សទា សោត្ថិ ករោតុ នោ ។

*សូមព្រះកិសាគោតមី អ្នកទ្រទ្រង់តំណែងកំពូលលើសជាង ភិក្ខុនីទាំងឡាយ អ្នកទ្រទ្រង់ចីវរសៅហ្មង ចូរប្រទាននូវសួស្តី ដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៨៤] សិង្គាលមាតា ភិក្ខុនី    សទ្ធាធិមុត្តានមុត្តមា

ករោតុ នោ មហាសន្តិ    អារោគ្យញ្ច សុខំ សទា ។

*សូមព្រះសិង្គាលមាតាភិក្ខុនី ជាកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកបង្អោនទៅដោយសទ្ធា ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែង សុខភាពល្អ និងសេចក្តីសុខដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៨៥] អញ្ញា ភិក្ខុនិយោ សព្វា នានាគុណាធរា ពហូ

ចាលេន្តុ នោ សព្វភយា សោករោគាទិសម្ភវា ។

*សូមភិក្ខុនីដទៃច្រើនព្រះអង្គ អ្នកទ្រទ្រង់គុណធម៌ផ្សេងៗ ចូរគ្រប់គ្រងនូវខ្ញុំទាំងឡាយឲ្យផុតចាកភ័យទាំងពួង ដែលកើតអំពីសេចក្តីសោក និងរោគភ័យជាដើម ។*

[១៨៦] សោតាបន្នាទយោ សេក្ខា សទ្ធាបញ្ញាសីលាធិកា

ភាគសោ ក្លេសទហានា សទា សោត្ថឹ ករោន្តុ នោ។

*សូមព្រះភិក្ខុនីជាសេក្ខបុគ្គល មានសោតាបន្នជាដើម អ្នកក្រៃលែងដោយសទ្ធា បញ្ញា និងសីល ជាអ្នកដុតកិលេសបានចំណែកខ្លះ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ស្តេចនាគ

[១៨៧] សុមនោ សុមនចលោ អរ៉ាឡ្យេបត្តកោ

ចម្បេយ្យោ មុចលិន្ទោ ច កម្ពលោ ភុជគិស្សរោ ។

*សុមននាគរាជ សុមនចលនាគរាជ អរវាឡនាគរាជ*
*ឯរបត្តកនាគរាជ ចម្បេយ្យនាគរាជ មុចលិន្ទនាគរាជ*
*និងកម្ពលនាគរាជ ជាស្តេចនាគ ។*

[១៨៨] កាលនាគោ មហាកាឡោ សង្ខបាលោ មហោទរោ
មណិកណ្ណោ មណិអក្ខិ នន្ទនាគោបនន្ទកោ។

*កាលនាគរាជ មហាកាឡនាគរាជ សង្ខបាលនាគរាជ*
*មហោទរនាគរាជ មណិកណ្ណនាគរាជ មណិអក្ខិនាគរាជ*
*នន្ទនាគរាជ និងឧបនន្ទនាគរាជ ។*

[១៨៩] វរុណោ ធតរដ្ឋោ ច កុន្ទិលោបលាលកោ
ចិត្រនាគោ មហាវីរោ ធព្យាបុត្តោ ច វាសុកិ ។

*វរុណនាគរាជ ធតរដ្ឋនាគរាជ កុន្ទិលនាគរាជ អបលាល-*
*នាគរាជ ចិត្រនាគរាជ មហាវីរនាគរាជ ធព្យាបុត្តនាគរាជ*
*និងវាសុកីនាគរាជ ។*

[១៩០] កណ្ហាគោតមោ ភុជគិន្ទោ អគ្គិធូមសិខោ តថា
ចូឡោទរោ អហិច្ឆត្តោ នាគា ឯរាបថាទយោ។

*កណ្ហាគោតមនាគរាជ ដែលជាស្តេចនាគ អគ្គិសិខនាគរាជ*
*ធូមសិខនាគរាជ ចូឡោទរនាគរាជ អហិច្ឆត្តនាគរាជ និងនាគ*
*ទាំងឡាយ មានឯរាបថនាគរាជជាដើម ។*

[១៩១] អាសីវិសា ឃោរវិសា យេ សព្វេ នយនាវុធា

ជលដ្ឋា វា ថលដ្ឋា វា បព្វតេយ្យា នទីចរា

ករោន្តុ នោ មហាសោត្ថិំ អាយុមារោគិយំ សទា ។

*នាគរាជពួកណាមានពិសដ៏ខ្លាំងក្លា មានពិសគួរឲ្យភ័យខ្លាច មានភ្នែកជាអាវុធ ទោះនៅក្នុងទឹក នៅលើគោក នៅក្នុងភ្នំ ឬនៅក្នុងស្ទឹង សូមនាគទាំងឡាយនោះ ចូរប្រទាននូវសួស្តីដ៏ធំក្រៃលែង អាយុ និងសុខភាពល្អ ដល់ខ្ញុំទាំងឡាយសព្វៗកាល ។*

## ប្រេត

[១៩២] និជ្ឈាមតណ្ហិកា បេតា ឧសុសត្តិ ច លោមកា

មំសបិណ្ឌានយោ បេតា បេតា វេមានិកានយោ

ចាលេន្តុ នោ សព្វភយា សទា តេ សុខិនោ សទា ។

*និជ្ឈាមតណ្ហិកប្រេត ឧសុលោមកប្រេត សត្តិលោមកប្រេត មំសបិណ្ឌប្រេត និងវេមានិកប្រេតជាដើម សូមប្រេតទាំងនោះ ចូរមានសេចក្តីសុខគ្រប់កាល ចូរគ្រប់គ្រងនូវខ្ញុំទាំងឡាយ ឲ្យផុតចាកភ័យទាំងពួង សព្វៗកាល ។*

## អសុរ

[១៩៣] យេ បហារាទសម្ពរ- ពល្យាសុរគណា ច យេ

វេបចិត្តាសុរគណា ចន្ទាសុរគណានយោ ។

*ពួកអសុរណា គឺពួកបហារាទអសុរ ពួកសម្ពរអសុរ ពួកពលិអសុរ ពួកវេបចិត្តអសុរ និងពួកចន្ទអសុរជាដើម ។*

[១៩៤] សព្វេ តេបិ មហាតេជា ភូតយក្ខនិវារណា

ករោន្តុ នោ មហាសោត្ថិំ អារោគ្យញ្ច ជយំ សទា ។

*សូម្បីពួកអសុរទាំងអស់នោះ ជាអ្នកមានតេជះច្រើន ជាទីរារាំងភូតនិងយក្ខ ចូរប្រទាននូវសួស្តីដ៏ធំក្រៃលែង សុខភាពល្អ និងជ័យជម្នះដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

**ទេវតា**

[១៩៥] យេ យក្ខា សត្តសហស្សា កុម្មា កាបិលវត្ថុកា

ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ ។

*យក្ខជាកុម្មទេវតាប្រាំពីរពាន់ណា នៅក្នុងក្រុងកបិលពស្តុ ទ្រទ្រង់ឥទ្ធិឫទ្ធិ មានរស្មីរុងរឿង មានសម្បុរល្អ បរិបូណ៌ដោយបរិវារ ។*

[១៩៦] សព្វេ តិសរណា យក្ខា មហេសក្ខា ជុតិន្ធរា

ករោន្តុ នោ មហាសោត្ថិំ អារោគ្យញ្ច ជយំ សទា ។

*យក្ខទាំងឡាយទាំងពួង ដែលមានព្រះរតនត្រ័យជាទីពឹង មានស័ក្តិធំ ទ្រទ្រង់នូវពន្លឺ សូមយក្ខទាំងនោះ ចូរប្រទាននូវសួស្តីដ៏ធំក្រៃលែង សុខភាពល្អ និងជ័យជម្នះដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៩៧] ឆសហស្សា ហេមវតា យក្ខា នានត្តវណ្ណិនោ
ពុទ្ធបូជាយ និរតា សទា សោត្ថឹ ករោន្តុ នោ ។

*សូមយក្ខប្រាំមួយពាន់ ដែលនៅក្នុងព្រៃហិមពាន្ត មានសម្បុរផ្សេងៗគ្នា ត្រេកអរក្នុងការបូជានូវព្រះពុទ្ធជាម្ចាស់ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៩៨] សាតាគិរា តិសហស្សា យក្ខា នីលាទិវណ្ណិនោ
នានាបភាយ សម្បន្នា សទា សោត្ថឹ ករោន្តុ នោ ។

*សូមយក្ខបីពាន់ ដែលនៅលើភ្នំសាតាគិរី មានសម្បុរខៀវជាដើម បរិបូណ៌ដោយពន្លឺផ្សេងៗ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៩៩] វេស្សាមិត្តា បញ្ចសតា យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ សទា សោត្ថឹ ករោន្តុ នោ ។

*សូមយក្ខប្រាំរយ ដែលនៅលើភ្នំវេស្សាមិត្ត មានសម្បុរផ្សេងៗគ្នា ទ្រទ្រង់នូវឫទ្ធិ មានរស្មី មានសម្បុរល្អ បរិបូណ៌ដោយបរិវារ រីករាយមកប្រជុំគ្នា ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២០០] កុម្ភីរោ រាជគហិកោ  វេបុល្លស្ស និវេសនំ

ភិយ្យោ នំ សតសហស្សំ យក្ខានំ បយិរុបាសតិ

យោ យក្ខេហិ បរិវារោ  សទា សោត្ថឹ ករោតុ នោ ។

*យក្ខឈ្មោះកុម្ភីរៈ ដែលនៅជិតក្រុងរាជគ្រឹះ មានភ្នំវេបុល្ល ជាវិមាន មានពួកយក្ខច្រើនសែនមកចូលមកប្រណិប័តន៍ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២០១] បុរិមញ្ច ទិសំ រាជា  ធតរដ្ឋោ បសាសតិ

គន្ធព្វានំ អធិបតិ  មហារាជា យសស្សិ សោ ។

*ស្តេចមហារាជព្រះនាមថា ធតរដ្ឋ គ្រប់គ្រងក្នុងទិសបូព៌ ជាអធិបតីរបស់ពួកគន្ធព្វ មានបរិវារច្រើន ។*

[២០២] បុត្តាបិ តស្ស ពហវោ  ឥន្ទនាមា មហព្វលា

សោ រាជា សហ បុត្តេហិ សទា សោត្ថឹ ករោតុ នោ ។

*សូម្បីបុត្ររបស់មហារាជក៏មានច្រើន មាននាមថា ឥន្ទៈដូចគ្នា សុទ្ធតែមានកម្លាំងច្រើន សូមស្តេចធតរដ្ឋនិងបុត្រទាំងឡាយ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២០៣] ទក្ខិណញ្ច ទិសំ រាជា  វិរុឡ្ហោ តំ បសាសតិ

កុម្ភណ្ឌានំ អធិបតិ  មហារាជា យសស្សិ សោ ។

ស្តេចមហារាជព្រះនាមថា វិរុឡ្ហកៈ គ្រប់គ្រងក្នុងទិសទក្សិណ
ជាអធិបតីរបស់ពួកកុម្ភណ្ឌ មានបរិវារច្រើន ។

[២០៤] បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា
វិរុឡ្ហោ សហ បុត្តេហិ សទា សោត្ថី ករោតុ នោ ។

សូម្បីបុត្ររបស់មហារាជក៏មានច្រើន មាននាមថា ឥន្ទៈដូច
គ្នា សុទ្ធតែមានកម្លាំងច្រើន សូមស្តេចវិរុឡ្ហកៈនិងបុត្រទាំង
ឡាយ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២០៥] បច្ឆិមញ្ច ទិសំ រាជា វិរូបក្ខោ បសាសតិ
នាគានញ្ច អធិបតិ មហារាជា យសស្សិ សោ ។

ស្តេចមហារាជព្រះនាមថា វិរូបក្ខៈ គ្រប់គ្រងក្នុងទិសបស្ចិម
ជាអធិបតីរបស់ពួកនាគ មានបរិវារច្រើន ។

[២០៦] បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា
វិរូបក្ខោ សហ បុត្តេហិ សទា សោត្ថី ករោតុ នោ ។

សូម្បីបុត្ររបស់មហារាជក៏មានច្រើន មាននាមថា ឥន្ទៈដូច
គ្នា សុទ្ធតែមានកម្លាំងច្រើន សូមស្តេចវិរូបក្ខៈនិងបុត្រទាំង
ឡាយ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២០៧] ឧត្តរញ្ច ទិសំ រាជា    កុវេរោ តំ បសាសតិ
យក្ខានញ្ច អធិបតិ    មហារាជា យសស្សិ សោ ។

*ស្តេចមហារាជព្រះនាមថា កុវេរៈ គ្រប់គ្រងក្នុងទិសឧត្តរ ជាអធិបតីរបស់ពួកយក្ខ មានបរិវារច្រើន ។*

[២០៨] បុត្តាបិ តស្ស ពហវោ    ឥន្ទនាមា មហាព្វលា
កុវេរោ សហ បុត្តេហិ    សទា សោត្ថី ករោតុ នោ ។

*សូម្បីបុត្ររបស់មហារាជក៏មានច្រើន មាននាមថា ឥន្ទៈដូចគ្នា សុទ្ធតែមានកម្លាំងច្រើន សូមស្តេចកុវេរៈនិងបុត្រទាំងឡាយ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២០៩] បុរិមំ ទិសំ ធតរដ្ឋោ    ទក្ខិណេន វិរុឡ្ហកោ
បច្ឆិមេន វិរូបក្ខោ    កុវេរោ ឧត្តរំ ទិសំ ។

*ស្តេចធតរដ្ឋៈ (នៅរក្សា) ខាងបុរិមទិស ស្តេចវិរុឡ្ហកៈ (នៅរក្សា)ខាងទក្ខិណទិស ស្តេចវិរូបក្ខៈ (នៅរក្សា)ខាង បច្ឆិមទិស ស្តេចកុវេរៈ (នៅរក្សា)ខាងឧត្តរទិស ។*

[២១០] ចត្តារោ តេ មហារាជា    សមន្តា ចតុរោ ទិសា
ពទ្ទល្លមានា អដ្ឋំសុ    សទា សោត្ថី ករោន្តុ នោ ។

*មហារាជទាំងឡាយ៤នោះ ជាអ្នកញ៉ាំងទិសទាំងបួនដោយ*

*ជុំវិញ ឲ្យរុងរឿង ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ
សព្វៗកាល ។*

[២១១] តេសំ មាយាវិនោ ទាសា អាគុំ វញ្ចនិកា សឋា
មាយា កុដេណ្ឌុ វិដេណ្ឌុ វិតុច្ច វិដុដោ សហ ។

*អ្នកបម្រើស្តេចមហារាជទាំងបួននោះ ជាអ្នកមានមាយា
បោកបញ្ឆោត មានលេស មកកាន់ទីប្រជុំ គឺអ្នកបម្រើ
ឈ្មោះកុដេណ្ឌុ វិដេណ្ឌុ វិតុច្ច និងវិដុដៈ ។*

[២១២] ចន្ទនោ កាមសេដ្ឋោ ច កិន្នុឃណ្ឌុ និឃណ្ឌុ ច
បនាទោ ឱបមញ្ញោ ច ទេវសូតោ ច មាតលិ ។

*ឈ្មោះចន្ទនៈ កាមសេដ្ឋៈ កិន្នុឃណ្ឌុ និឃណ្ឌុ បនាទៈ
ឱបមញ្ញៈ និងសារថីមាតលី ។*

[២១៣] ចិត្តសេនោ ច គន្ធព្វោ នឡោ រាជា ជនេសភោ
វកោ បញ្ចសិខោ ចេវ តិម្ពរូ សុរិយវច្ចសា ។

*គន្ធព្វឈ្មោះចិត្តៈ សេនៈ និងចិត្តសេនៈ ទេវបុត្រឈ្មោះ
នឡៈ ទេវបុត្រឈ្មោះជវនសភៈ ទេវបុត្រឈ្មោះបញ្ចសិខៈ
ទេពគន្ធព្វឈ្មោះតិម្ពរូ ទេពធីតាឈ្មោះសុរិយវច្ចសា ។*

[២១៤] ឯតេ ចញ្ញេ ច រាជានោ គន្ធព្វា ច មហាព្វលា
មោទមានា សទា សោត្ថិ ករោន្តុ នោ អនាមយំ ។

សូមទេព យក្ខ និងគន្ធព្វទាំងនោះ ព្រមទាំងទេវតាដទៃៗ
ជាអ្នកមានកម្លាំងច្រើន មានចិត្តរីករាយ ចូរប្រទាននូវ
សួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

## នាគ

[២១៥] មហន្តា នាគសា នាគា វេសាលា សហ តច្ឆកា

កម្ពលស្សតរា ចាបិ មេរុថានសិតា ពលា ។

ពួកនាគទាំងឡាយដ៏ច្រើន អាស្រ័យនៅក្នុងស្រះឈ្មោះថា
នាគសៈ នាគអាស្រ័យនៅក្នុងនគរវេសាលី ព្រមទាំងបរិវារ
របស់នាគតច្ឆកៈ កម្ពលនាគរាជ និងអស្សតរនាគរាជ ជា
អ្នកមានកម្លាំងខ្លាំងក្លា ស្ថិតនៅក្នុងភ្នំសុមេរុរាជ ។

[២១៦] យាមុនា ធតរដ្ឋា ច សព្វេ នាគា យសស្សិនោ

ឯរាវណោ មហានាគោ ករោន្តុ នោ អនាមយំ ។

នាគនៅក្នុងស្ទឹងយមុនា និងនាគធតរដ្ឋៈ នាគទាំងពួងនោះ
ព្រមទាំងបរិវារ និងស្តេចដំរីឯរាវណ ចូរប្រទាននូវ
សុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

## គ្រុឌ

[២១៧] មហិទ្ធិកា សុបណ្ណា យេ នាគរាជេ មហាព្វលេ

គហេត្វា ជិនខេត្តេវ បក្ខីសុ នភេ ពលា

តេ ពុទ្ធសរណា សព្វេ សោត្ថឹ ករោន្តុ នោ សទា។

គ្រុឌទាំងឡាយឯណា មានឫទ្ធិច្រើន កាលចាប់នាគរាជដែលមានកម្លាំងខ្លាំង ហើយហើរទៅកាន់អាកាសដែលជាខេត្តដែនឈ្មោះនាគដោយកម្លាំង គ្រុឌទាំងឡាយនោះ មានព្រះពុទ្ធជាសរណៈ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

## ទេវតា

[២១៨] បឋព្យាបោ ច តេជោ ច វាយោ ទេវា មហិទ្ធិកា
ឧបចារេន និព្វត្តា សទា សោត្ថី ករោន្តុ នោ ។

ទេវតាឈ្មោះបឋវី ឈ្មោះអាបោ ឈ្មោះតេជោ និងឈ្មោះវាយោ មានឫទ្ធិច្រើន កើតដោយឧបចារឈាន (ក្នុងបឋវីកសិណជាដើម) ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២១៩] វរុណា វារុណា ទេវា សោមោ ច យសសា សហ
មេត្តាការុណិកា សព្វេ សទា សោត្ថី ករោន្តុ នោ ។

ទេវតាឈ្មោះវរុណៈ ឈ្មោះវារុណា ឈ្មោះសោមៈ ព្រមទាំងទេវតាឈ្មោះយសៈ ម្យ៉ាងទៀត ទេវតាឈ្មោះមេត្តា គឺអ្នកកើតដោយការចម្រើនមេត្តា) និងឈ្មោះករុណា គឺអ្នកកើតដោយការចម្រើនករុណា) ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២២០] បណ្ណាសយោជនាយាមេ វិមានេ រតនាមយេ
ឋិតោ តមេ វិហន្ត្វាន សុរិយោ សោត្ថឹ ករោតុ នោ ។

*សូមសុរិយទេព ដែលស្ថិតនៅក្នុងវិមាន ៥០យោជន៍ ដែលសម្រេចហើយដោយរតនៈ ចូរកម្ចាត់នូវងងឹតហើយ ប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២១] ចន្ទោ សីតករោ លោកេ បភាយុជ្ជលិតោទយោ
មហន្ធការវិទ្ធំសី សទា សោត្ថឹ ករោតុ នោ ។

*សូមចន្ទទេពមានរស្មីរុងរឿង កម្ចាត់នូវងងឹតដ៏ធំ ឧទ័យឡើងភ្លឺស្វាងក្នុងលោក ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២២] វេណ្ឌុ ច សហាសីទេវា អសមា ច ទុវេ យមា
ចន្ទស្សូបនិសា ទេវា ទេវា សុរិយនិស្សិតា
ពុទ្ធស្ស មាមកា សព្វេ សទា សោត្ថឹ ករោន្តុ នោ ។

*ទេវតាឈ្មោះវេណ្ឌុ ឈ្មោះសហសី ឈ្មោះអសមៈ ព្រះយមទាំងពីរ ទេវតាដែលអាស្រ័យព្រះចន្ទ និងទេវតាដែលអាស្រ័យព្រះអាទិត្យ សូមទេវតាទាំងពួង ដែលរាប់កាន់ព្រះពុទ្ធជាម្ចាស់ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២៣] នក្ខត្តានិ បុរក្ខត្វា ទេវា មន្ទវលាហកា

សក្កោ បុរិន្ទទោ សេដ្ឋោ សទា សោត្ថឹ ករោន្តុ នោ ។

*ទេវតាឡោមព័ទ្ធនក្ខត្តឫក្ស ទេវតាខ្យល់ ទេវតាភ្លៀង ទេវតាមេឃ និងសក្កទេវរាជដ៏ប្រសើរដែលបានឲ្យទានក្នុងកាលមុន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២៤] មហន្តា សហភូ ទេវា ជលមគ្គិសិខារិវ

អរិដ្ឋកា ច រោជា ច ឧមាបុប្ផនិភាសិនោ ។

*ទេវតាឈ្មោះសហភូ ដ៏ធំរុងរឿងដូចភ្លើង អរិដ្ឋកទេព និងរោជទេព អ្នកមានរស្មីដូចផ្កាត្រកៀត ។*

[២២៥] វរុណា សហធម្មា ច អច្ចុតា ច អនេជកា

សូលេយ្យរុចិរា ទេវា ទេវា វាសវនេសិនោ

ទសេតេ ទសធា កាយា សទា សោត្ថឹ ករោន្តុ នោ ។

*ទេវតាឈ្មោះវរុណៈ ឈ្មោះសហធម្មៈ ឈ្មោះអច្ចុតៈ ឈ្មោះអនេជកៈ ឈ្មោះសូលេយ្យៈ ឈ្មោះរុចិរៈ និងឈ្មោះវាសវនេសី សូមទេពជប់ពួកៗ និងជប់ពួកទាំងនោះ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២៦] សមានា មហាសមានា មានុសា មានុសុត្តមា

ខិឌ្ឌាបទោសិកា ទេវា ទេវា មនោបទោសិកា ។

*ទេវតាឈ្មោះសមានៈ ឈ្មោះមហាសមានៈ ឈ្មោះមានុសៈ ឈ្មោះមានុសុត្តមៈ ឈ្មោះខិឌ្ឌាបទោសិកៈ និងឈ្មោះ មនោបទោសិកៈ ។*

[២២៧] អថាបិ ហារយោ ទេវា ទេវា លោហិតវាសិនោ

បារគា មហាបារគា សព្វេ ទេវា យសស្សិនោ

ទសេតេ ទសធា កាយា សទា សោត្ថឹ ករោន្តុ នោ ។

*ម្យ៉ាងទៀត ទេវតាឈ្មោះហរិ ឈ្មោះលោហិតវាសី ឈ្មោះ បារគៈ ឈ្មោះមហាបារគៈ ទេវតាទាំងពួងនោះ បរិបូណ៌ ដោយបរិវារ សូមទេពជប់ពួកៗ និងជប់ពួកទាំងនោះ ចូរ ប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២៨] សុក្កា ករុម្ហា អរុណា អាគុំ វេឃនសា សហ

ឱទាតគយ្ហា បាមោក្ខា អាគុំ ទេវា វិចក្ខណា ។

*ទេវតាឈ្មោះសុក្កៈ ឈ្មោះករុម្ហៈ ឈ្មោះអរុណៈ មកហើយ ព្រមទាំងវេឃនសទេព ទេវតាឈ្មោះឱទាតគយ្ហៈ ជាប្រធាន ទេវតាឈ្មោះវិចក្ខណៈ ក៏មកព្រមគ្នា ។*

[២២៩] សទាមត្តា ហារគជា មិស្សកា ច យសស្សិនោ

ថនយំ អាគ បជ្ជុន្នោ យោ ទិសា អភិវស្សតិ ។

*ទេវតាឈ្មោះសទាមត្តៈ ឈ្មោះហារគជៈ ឈ្មោះមិស្សកៈ បរិបូណ៌ដោយបរិវារ និងបជ្ជុន្នទេព ដែលផ្គរឲ្យភ្លៀងធ្លាក់គ្រប់ទិស ក៏មកព្រមគ្នា ។*

[២៣០] ទសេតេ ទសធា កាយា សព្វេ នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា ជិនទានា សទា សោត្ថឹ ករោន្តុ នោ ។

*ពួកទេពដប់ពួកៗ និងដប់ពួកទាំងនោះ មានសម្បុរផ្សេងៗគ្នា មានឫទ្ធិច្រើន មានអានុភាពច្រើន មានសម្បុរល្អ បរិបូណ៌ដោយបរិវារ រីករាយចិត្ត ដែលឲ្យនូវជ័យជម្នះ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៣១] លោកធាតុសហស្សេសុ ទសស្វេវ សមន្តតោ
ទេវាទយោ បាណាគណា សទា សោត្ថឹ ករោន្តុ នោ ។

*សូមពួកសត្វមានទេវតាជាដើម ក្នុងមុឺនលោកធាតុដោយជុំវិញនោះឯង ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយសព្វៗកាល ។*

[២៣២] ខេមិយា កដ្ឋកាយា ច ជោតិនាមា មហិទ្ធិកា
លម្ពីតកា លាមសេដ្ឋា សទា សោត្ថឹ ករោន្តុ នោ ។

*ទេវតាឈ្មោះខេមិយៈ ឈ្មោះកដ្ឋកាយៈ ឈ្មោះជោតិ មាន*

*ឫទ្ធិច្រើន ទេវតាឈ្មោះលម្ពីតកា និងឈ្មោះលាមសេដ្ឋៈ*
*ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៣៣] ជលដ្ឋា ច ថលដ្ឋញ្ញោ ទេវាកាសដ្ឋកានយោ
យក្ខគន្ធព្វកុម្ភណ្ឌា បិសាចា យេ មហោរគា
មេត្តចិត្តា ច សព្វេ តេ សោត្ថី ជាសុំ ករោន្តុ នោ ។

*ទេវតាដែលនៅក្នុងទឹក ទេវតានៅលើគោក និងទេវតាដែលនៅក្នុងអាកាស ជាដើមពួកដទៃ យក្ខ គន្ធព្វ កុម្ភណ្ឌ បិសាច និងនាគរាជទាំងអស់ ចូរមានមេត្តាចិត្ត សូមប្រទាននូវផាសុកគឺសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៣៤] តាវតឹសា ច យេ ទេវា យាមា ទេវា មហិទ្ធិកា
តុសិតា ច មហាទេវា និម្មានរតិនោមរា ។

*ទេវតាឯណានៅជាន់តាវត្តិង្ស ជាន់យាមា មានឫទ្ធិច្រើន ទេវតាដ៏ធំជាន់តុសិត ជាន់និម្មានរតី ។*

[២៣៥] វសវត្តីស រតិនោ សព្វេ ទេវា សវាសវា
ពុទ្ធបូជាយ និរតា សទា សោត្ថី ករោន្តុ នោ ។

*ម្យ៉ាងទៀត ទេវតាជាន់បរិនិម្មិតវសវតី សូមទេវតាទាំងពួងព្រមទាំងស្តេចវាសវៈ អ្នកត្រេកអរក្នុងពុទ្ធបូជា ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## **ព្រហ្ម**

[២៣៦] ព្រហ្មានោ ចារិសជ្ជា ច   យេ ច ព្រហ្មបុរោហិតា
មហាព្រហ្មា ច សព្វេ តេ  បឋមជ្ឈានសណ្ឋិនោ ។
*ព្រហ្មទាំងឡាយឯណា ជាន់បារិសជ្ជា ជាន់បុរោហិតា និង ព្រហ្មជាន់មហាព្រហ្ម ព្រហ្មទាំងអស់នោះ ទ្រទ្រង់ក្នុង បឋមជ្ឈាន ។*

[២៣៧] មេត្តាវិហារិនោ សន្តា   សម្ពុទ្ធស្ស បរាយនា
ករោន្តុ នោ មហាសោត្ថឹ សេក្ខាសេក្ខបុថុជ្ជនា ។
*ព្រហ្មទាំងនោះ នៅដោយមេត្តាជាប្រក្រតី ជាអ្នកស្ងប់ មានមុខឆ្ពោះទៅរកព្រះសម្ពុទ្ធ ទោះជាបុថុជ្ជន សេក្ខៈ និង អសេក្ខៈ ចូរប្រទាននូវសួស្តីដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៣៨] បរិត្តាភាប្បមាណាភា   ព្រហ្មា ចាកស្សរា តថា
ពុទ្ធុប្បជាយ ចិរតា   ទុតិយជ្ឈានសណ្ឋិនោ ។
*ព្រហ្មជាន់បរិត្តាភា ព្រហ្មជាន់អប្បមាណាភា និងព្រហ្មជាន់ អាភស្សរា ជាអ្នកត្រេកអរក្នុងពុទ្ធុប្បាទ ទ្រទ្រង់នៅក្នុង ទុតិយជ្ឈាន ។*

[២៣៩] មេត្តាការុណិកា សព្វេ   សព្វសត្តហិតេសិនោ
ករោន្តុ នោ មហាសន្តឹ   សោត្ថិមារោគ្យមាយុវំ ។

*ព្រហ្មទាំងអស់នោះ ប្រកបដោយមេត្តា និងករុណា ស្វែងរកប្រយោជន៍ផ្គូផ្គងដល់ជនទាំងពួង ចូរប្រទាននូវការស្ងប់ដ៏ធំក្រៃលែង សួស្តី សុខភាពល្អ និងអាយុវែងដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៤០] បរិត្តសុភាព្រហ្មានោ អប្បមាណសុភា ច យេ
សុភាកិណ្ហា ច ព្រហ្មានោ តតិយជ្ឈានសណ្ឋិនោ ។

*ព្រហ្មទាំងឡាយឯណា ឈ្មោះព្រហ្មជាន់បរិត្តសុភា ព្រហ្មជាន់អប្បមាណសុភា និងព្រហ្មជាន់សុភាកិណ្ហា ព្រហ្មទាំងអស់នោះ ទ្រទ្រង់នៅក្នុងតតិយជ្ឈាន ។*

[២៤១] បភាយ ផរណា លោកេ ពុទ្ធជ្ឈានរតា សទា
អហឹសា សព្វសត្តេសុ សទា សន្តឹ ករោន្តុ នោ ។

*ព្រហ្មទាំងនោះផ្សាយរស្មីទៅក្នុងលោក ត្រេកអរក្នុងការរលឹកដល់ព្រះពុទ្ធ ជាអ្នកមិនបៀតបៀនសត្វលោកទាំងមូល ចូរប្រទាននូវសេចក្តីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៤២] វេហាប្ផលាបិ ព្រហ្មានោ ចតុត្ថជ្ឈានសណ្ឋិនោ
សេក្ខបុថុជ្ជនាសេក្ខា សទា សន្តឹ ករោន្តុ នោ ។

*សូម្បីព្រហ្មជាន់វេហប្ផលា ទ្រទ្រង់នៅក្នុងចតុត្ថជ្ឈាន ទោះជាបុថុជ្ជន សេក្ខៈ និងអសេក្ខៈ ចូរ ប្រទាននូវសេចក្តីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៤៣] សម្បត្តិយា ន ហាយន្តិ ព្រហ្មានោ ជិនសាវកា
អវិហានាមកា សព្វេ សទា សន្តិំ ករោន្តុ នោ ។

*ពួកព្រហ្មទាំងអស់ ជាសាវករបស់ព្រះជិនស្រី រមែងមិនវិនាសចាកសម្បត្តិ ទើបបានឈ្មោះថា អវិហា ចូរប្រទាននូវសេចក្ដីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៤៤] អតប្បា នាម ព្រហ្មានោ ចតុត្ថជ្ឈានសណ្ឋិនោ
ព្រហ្មវិហារិកា សព្វេ សោត្ថិំ ជាសុំ ករោន្តុ នោ ។

*ពួកព្រហ្មទាំងអស់ ទ្រទ្រង់នៅក្នុងចតុត្ថជ្ឈាន បរិបូណ៌ដោយព្រហ្មវិហារ ចូរប្រទាននូវផាសុក គឺសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៤៥] សុទស្សា នាម ព្រហ្មានោ–ភិរូទា ឈានភោគិនោ
អបុនាគមនា កាមេ សន្តិំ ជាសុំ ករោន្តុ នោ ។

*ពួកព្រហ្មឈ្មោះថា សុទស្សា មានរូបស្អាត សោយឈានជាអ្នកមិនត្រឡប់មកកាន់កាមភូមិទៀត ចូរប្រទាននូវផាសុកគឺសេចក្ដីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៤៦] ព្រហ្មវិហារសម្បន្នា ជិនភត្តិបរាយនា
ព្រហ្មានោ សុទស្សី នាម សទា សោត្ថិំ ករោន្តុ នោ ។

ពួកព្រហ្មឈ្មោះថា សុទស្សី ដល់ព្រមហើយដោយព្រហ្ម-
វិហារ មានភក្តីក្នុងព្រះជិនស្រី ជាទីតាំង ចូរប្រទាននូវ
សួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២៨៧] អកនិដ្ឋា ច ព្រហ្មានោ ជេដ្ឋា សព្វគុណេហិ ច
បហីនភាវនិស្នេហា សទា សោត្ថី ករោន្តុ នោ ។

ពួកព្រហ្មឈ្មោះថា អកនិដ្ឋា ដ៏ប្រសើរដោយគុណទាំងពួង
កម្ចាត់សេចក្តីស្រឡាញ់ក្នុងភពបានហើយ ចូរប្រទាននូវ
សួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២៨៨] បឋមារូបព្រហ្មានោ សព្វរូបវិរាគិនោ
ជិនភត្តិរតា សព្វេ សទា សោត្ថី ករោន្តុ នោ ។

អរូបព្រហ្មជាន់ទី ១ ទាំងពួង ជាអ្នកមិនជាប់ជំពាក់ក្នុងរូប
ត្រេកអរក្នុងភក្តីចំពោះព្រះជិនស្រី ចូរប្រទាននូវសួស្តី
ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២៨៩] ទុតិយារូបព្រហ្មានោ ហេដ្ឋាឈានវិរាគិនោ
ជិនភត្តិរតា សព្វេ សទា សោត្ថី ករោន្តុ នោ ។

អរូបព្រហ្មជាន់ទី ២ ទាំងពួង ជាអ្នកមិនពេញចិត្តក្នុងឈាន
ជាន់ទាប ត្រេកអរក្នុងភក្តីចំពោះព្រះជិនស្រី ចូរប្រទាននូវ
សួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២៥០] តតិយារូបព្រហ្មានោ ហេដ្ឋាឈានវិរាគិនោ

ជិនភត្តិរតា សព្វេ សទា សោត្ថឹ ករោន្តុ នោ ។

*អរូបព្រហ្មជាន់ទី ៣ ទាំងពួង ជាអ្នកមិនពេញចិត្តក្នុងឈាន ជាន់ទាប ត្រេកអរក្នុងភក្តីចំពោះព្រះជិនស្រី ចូរប្រទាននូវ សួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៥១] ចតុត្ថារូបព្រហ្មានោ ហេដ្ឋាឈានវិរាគិនោ

ជិនភត្តិរតា សព្វេ សទា សោត្ថឹ ករោន្តុ នោ ។

*អរូបព្រហ្មជាន់ទី ៤ ទាំងពួង ជាអ្នកមិនពេញចិត្តក្នុងឈាន ជាន់ទាប ត្រេកអរក្នុងភក្តីចំពោះព្រះជិនស្រី ចូរប្រទាននូវ សួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ប្រភេទរួមបុគ្គល

[២៥២] វេទេហាបរគោយានេ ជម្ពុទីបេ កុរុម្ហិ ច

ទេវយក្ខបិសាចេហិ សទ្ធឹ វិជ្ជាធរាទយោ ។

*ពួកវិជ្ជាធរជាដើម ព្រមទាំងទេវតា យក្ខ និងបិសាច ក្នុងវេទេហទ្វីប អបរគោយានទ្វីប ជម្ពូទ្វីប និងឧត្តរកុរុទ្វីប។*

[២៥៣] អាកាសដ្ឋា ច ព្រហ្មានោ ជលដ្ឋា ចន្តលិក្ខជា

ទ្វិបទាទយោ យេ សត្តា សទា សោត្ថឹ ករោន្តុ នោ ។

ពួកព្រហ្មស្ថិតនៅក្នុងអាកាស និងសត្វជើងពីរជាដើម ដែលស្ថិតនៅក្នុងទឹក ឬអាកាស ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

## អានុភាពព្រះរតនត្រ័យ

[២៥៤] មារសេនវិយាតាយ ជិនស្ស សុខឈាយនោ
តេជោពលេន មហាតា សទា មង្គលមត្ថុ នោ ។

ដោយតេជានុភាពដ៏ធំក្រៃលែងរបស់ព្រះជិនស្រី ព្រះអង្គទ្រង់មានសេចក្តីសុខក្នុងឈាន ព្រោះបានកម្ចាត់បង់នូវមារាធិរាជព្រមទាំងសេនា សូមមង្គលចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។

[២៥៥] នានាគុណវិចិត្តស្ស រូបកាយស្ស សត្ថុនោ
សព្វទេវមនុស្សានំ មារពន្ធវិមោចិនោ
មេត្តាពលេន មហាតា សទា មង្គលមត្ថុ នោ ។

ដោយតេជានុភាពនៃព្រះមេត្តាដ៏ធំក្រៃលែងនៃព្រះរូបកាយដ៏វិចិត្រផ្សេងៗរបស់ព្រះសាស្តា ព្រះអង្គទ្រង់ញុំាងទេវតានិងមនុស្សទាំងពួង ឲ្យរួចផុតចាកគ្រឿងចំណងរបស់មារ សូមមង្គលចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។

[២៥៦]សព្វញ្ញុតានិកាយស្ស ធម្មកាយស្ស សត្ថុនោ
ចក្ខាទ្យគោចរស្សាបិ គោចរស្សេវ ភូរិយា
តេជោពលេន មហតា សព្វមង្គលមត្ថុ នោ ។

*ដោយតេជានុភាពដ៏ធំក្រៃលែងនៃព្រះធម្មកាយ ដែលមានព្រះសព្វញ្ញុតញ្ញាណជាដើមរបស់ព្រះសាស្ដា សូមមង្គលទាំងពួងចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

[២៥៧]រូបកាយសនិសស្ស និម្មិតស្ស មហេសិនោ
ធម្មស្ស វត្ថុនោ សគ្គេ ទេវានំ សុគតា បតិ
តេជោពលេន មហតា សទា មង្គលមត្ថុ នោ ។

*ដោយតេជានុភាពដ៏ធំក្រៃលែងនៃព្រះពុទ្ធនិម្មិត ដែលព្រះពុទ្ធជាម្ចាស់ទ្រង់និម្មិតហើយ ដូចជាព្រះរូបកាយរបស់ព្រះអង្គជាអ្នកស្វែងរកនូវគុណដ៏ធំ សម្ដែងធម៌ដល់ទេវតាទាំងឡាយក្នុងស្ថានតាវត្តិង្ស សូមមង្គលចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

[២៥៨]សិក្ខិត្វា មានុសេ ទេវេ មោចយិត្វា សទេវកេ
សង្ខារេ បជហន្តស្ស និព្វុតស្ស មហេសិនោ
មហានេក្ខានុភាវេន សព្វមង្គលមត្ថុ នោ ។

ដោយតេជានុភាពដ៏ធំក្រៃលែងរបស់ព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ជាអ្នកស្វែងរកនូវគុណធំ ព្រះអង្គទ្រង់បង្រៀននូវទេវតានិងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ញុំាងទេវតានិងមនុស្សទាំងឡាយ ឲ្យរួចផុតចាកអន្ទាក់របស់មារ លះសង្ខារទាំងឡាយបរិនិព្វានហើយ សូមមង្គលទាំងពួងចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។

[២៥៩]ចតុរាសីតិសហស្ស　　ធម្មក្ខន្ធស្ស តេជសា

នវង្គសាសនស្សាបិ　　នវលោកុត្តរស្ស ច

សព្វបាបបវាហេន　　សព្វមង្គលមត្ថុ នោ ។

ដោយតេជានុភាពនៃព្រះធម៌ ៨៤,០០០ ព្រះធម្មក្ខន្ធ នវង្គសត្ថុសាសន៍ និងនវលោកុត្តរធម៌ ដែលនាំបាបទាំងពួងចេញហើយ សូមមង្គលទាំងពួង ចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។

[២៦០]មហាគោរិយសង្ឃស្ស　　បុញ្ញក្ខេត្តស្ស តាទិនោ

បហីនសព្វបាបស្ស　　សីលាទិក្ខន្ធធារិនោ

មហាតេជានុភាវេន　　សព្វមង្គលមត្ថុ នោ ។

ដោយតេជានុភាពដ៏ធំក្រៃលែងនៃព្រះអរិយសង្ឃ ជាស្រែបុណ្យ ដែលមិនកម្រើកញាប់ញ័រ ជាអ្នកលះបាបទាំងពួងហើយ ទ្រទ្រង់នូវគុណមានសីលជាដើម សូមមង្គលទាំងពួងចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។

## អានុភាពទេវតា

[២៦១]ទាតាលេ ភូតលាកាសេ ទេវយក្ខបិសាចកា

វិជ្ជាធរា ច គន្ធព្វា នាគកុម្ភណ្ឌរក្ខសា

សព្វេសមានុភាវេន សព្វមង្គលមត្ថុ នោ ។

*ដោយតេជានុភាពនៃសត្វទាំងពួង គឺទេវតា យក្ខ បិសាច វិជ្ជាធរ គន្ធព្វ នាគ កុម្ភណ្ឌ និងរក្ខសទេវតាទាំងឡាយ ដែលស្ថិតនៅក្រោមផែនដី លើផែនដី និងក្នុងអាកាស សូមមង្គលទាំងពួង ចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

## អានុភាពនៃឧប្បាតសន្តិ

[២៦២]ឥច្ចេវមុប្បាតសន្តឹ យោ វទេយ្យ សុណេយ្យ វា

វិជេយ្យ សព្វទាទានិ វុឌ្ឍត្តញ្ច ភវិស្សតិ ។

*បុគ្គលណាស្វាធ្យាយ ឬស្តាប់ឧប្បាតសន្តិ ដែលខ្ញុំពោលមកហើយយ៉ាងនេះ បុគ្គលនោះ គប្បីឈ្នះបាបទាំងពួង នឹងមានសេចក្តីចម្រើនរុងរឿង ។*

[២៦៣] សោត្ថិកាមោ លភេ សោត្ថឹ សុខកាមោ សុខំ លភេ

អាយុកាមោ លភេយ្យាយុំ បុត្តកាមោ លភេ បុត្តេ។

*អ្នកប្រាថ្នានូវសួស្តី រមែងបាននូវសួស្តី អ្នកប្រាថ្នាសុខ រមែង*

*បានសុខ អ្នកប្រាថ្នាអាយុ រមែងបានអាយុ អ្នកប្រាថ្នាបុត្រ រមែងបានបុត្រ ។*

[២៦៤] ន តស្ស រោគា ពាធេន្តិ វាតបិត្តាទិសម្ភវា
អកាលមរណំ នត្ថិ ន ទេវា វិសមោសរេ ។

*រោគកើតពីខ្យល់និងប្រមាត់ជាដើម រមែងមិនបៀតបៀនបុគ្គលនោះ សេចក្ដីស្លាប់មុនកាល រមែងមិនមាន ទេវតាមិនបៀតបៀនឲ្យធ្លាក់ចុះ ។*

[២៦៥] ន ចុប្បាតភយំ តស្ស នោបិ បត្តភយំ តថា
នស្សន្តិ ទុន្និមិត្តានិ ចាបកម្មដ្ឋិតានិ ច
ទីឃមាយុ មហាសោត្ថី អារោគ្យញ្ច សទា ភវេ ។

*ភ័យគឺហេតុអាក្រក់ រមែងមិនមាន ភ័យចំពោះមុខ នឹងមិនកើតឡើង និមិត្តអាក្រក់និងបាបគ្រោះ រមែងវិនាសទៅ ការមានអាយុវែង សិរីសួស្ដីដ៏ធំ ការមិនមានរោគ នឹងគប្បីមាន (ដល់បុគ្គលអ្នកស្វាធ្យាយ ឬអ្នកស្ដាប់) ។*

[២៦៦] យោ សុត្វាបិ មហាសន្តឹ សង្គាមំ បវិសេ នរោ
វិជយេ វេរិនោ សព្វេ ន សត្ថេហ្យភិភូយតេ។

*បុគ្គលណាស្ដាប់ឧប្បាតសន្តិដ៏ប្រសើរហើយ គប្បីចូលទៅកាន់សង្គ្រាម នឹងឈ្នះសឹកសត្រូវ សាស្ត្រាវុធមិនអាចមុតបានឡើយ ។*

[២៦៧] សព្វទា លភតេ បីតឹ   វិបត្តឹ នាវគាហតិ

ភោគេហិ នាភិក្ខយតេ   សវត្ថុហិ វិវឌ្ឍតេ ។

*រមែងបានទទួលនូវបីតិសព្វៗកាល មិនមានវិបត្តិ មិនមាន ភោគបៀតបៀន រមែងចម្រើនដោយទ្រព្យ ។*

[២៦៨] យត្រ ទេសេ មហោរគា   ពាឡ្ហកា រក្ខសាទយោ

ឧប្បាតសន្តិឃោសេន   សព្វេ តត្ថ សមន្តិ តេ ។

*ពស់ធំនិងអារក្សទឹកជាដើមដែលអាក្រក់ នៅក្នុងទីណា ទាំងអស់នោះ រមែងស្ងប់ទៅក្នុងស្ថានទីនោះ ដោយ សំឡេងស្វាធ្យាយឧប្បាតសន្តិ ។*

[២៦៩] យមុទ្ទិស្សរវេ សន្តឹ   សជីវញ្ចាប្យជីវិតំ

សោ មុច្ចតេ មហាទុក្ខា   បប្បោតិ សុគតឹ សទា ។

*បុគ្គលស្វាធ្យាយឧប្បាតសន្តិ ដោយឧទ្ទិសឲ្យអ្នកណា ដែល មានជីវិតរស់នៅ ឬមិនមានជីវិត រមែងរួចផុតចាកទុក្ខដ៏ធំ រមែងដល់នូវសុគតិភព ។*

[២៧០] ទេវដ្ឋានេ នគរេ វា   និច្ចមុប្បាតសន្តិយា

ចាលកា ទេវរាជានោ   តេជសិរីវិវឌ្ឍនា។

*ទេវតារក្សាទេវដ្ឋាន ឬក្នុងព្រះនគរ ជាអ្នកចម្រើនដោយតេជះ និងសិរីមង្គល ដោយឧប្បាតសន្តិ ដែលស្វាធ្យាយឧទ្ទិសឲ្យ។*

[២៧១] បថព្យាទាទិសញ្ជាតា ឧប្បាតា ចន្ទលិក្ខជា
ឥន្ទាទិជនិតុប្បាតា ទាបកម្មសមុដ្ឋិតា
សព្វុប្បាតា វិនស្សន្តិ តេជសុប្បាតសន្តិយាតិ ។

*ហេតុអាក្រក់ដែលកើតពីផែនដី និងទឹកជាដើម ដែលកើតពីអាកាស ដែលកើតពីចន្ទគ្រាសជាដើម ឬដែលកើតពីបាបកម្ម ហេតុអាក្រក់ទាំងអស់នោះ នឹងវិនាសទៅដោយតេជះនៃឧប្បាតសន្តិ ។*

**ឧប្បាតសន្តិ និដ្ឋិតា។**

**ចប់ឧប្បាតសន្តិ**

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាន

ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់

(The Corporate Body of the Buddha Educational Foundation) ។

ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុង-
រឿងក្នុងលោក


ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់
នៅកន្លែងណា ឬចង់បានសៀវភៅធម៌យកទៅអាន
សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ
វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
លេខទូរស័ព្ទៈ (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩
អ៊ីមែលៈ maha.panna@gmail.com
គេហទំព័រៈ http://www.mahapanna.org

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~